ឈូកា ម៉ឹង ម៉ៅ
អធិការបឋមសិក្សា
ចាងហ្វាងក្រសួងកិច្ចការគរុកោសល្យភ្នំពេញ

# សុភាវធម៌

## តាមកម្មវិធីថ្មី នៃ បឋមសិក្សាជាតិ

រោងពុម្ពរស្មី

រក្សាសិទ្ធគ្រប់យ៉ាង

ឈ្មោះ ម៉ឺង ម៉ៅ

អធិការបឋមសិក្សា

ចាងហ្វាងក្រសួងកិច្ចការគរុកោសល្យភ្នំពេញ

# សុភាសិតធម៌

តាមកម្មវិធីថ្មី នៃបឋមសិក្សាជាតិ

បោះពុម្ពលើកទី១

រក្សាសិទ្ធិគ្រប់យ៉ាង

រោងពុម្ពរស្មី

ព.ស.២៥០៣ គ.ស.១៩៦០

# មាតិការឿង

អំពីសុភាវធម៌ ឬភាពសមរម្យ

សុភាវធម៌តាមកម្មវិធីថ្មី

វត្ថុបំណងរបស់សៀវភៅនេះ

ការទស្សនាអំពីសុភាវធម៌

សេចក្ដីសង្កេត

លំនាំដើម

ជំពូកទី ១ សុភាវធម៌នៅឯគេហដ្ឋាន

ទី២ សុភាវធម៌ចំពោះភ្ញៀវពន្លឺ

ទី៣ សុភាវធម៌ចំពោះអ្នកមកស៊ីឈ្នួល នៅធ្វើការក្នុងគ្រួសារយើង

ទី៤ សុភាវធម៌នៅពេលបរិភោគ

ទី៥ សុភាវធម៌នៅសាលារៀន

ទី៦ អាកប្បកិរិយាដែលត្រូវប្រព្រឹត្ត នៅកន្លែងសាធារណៈ

ទី៧ សុភាវធម៌នៅពិធីបុណ្យសាសនា និងនៅវត្តអារាម

ទី៨ សុភាវធម៌ចំពោះជនបរទេស

ទី៩ យុវជនយើង និងការសរសេរសំបុត្រ

# ព្រះរាជាណាចក្រកម្ពុជា

លេខ១៥៤៦

ចុះថ្ងៃទី ១ - ៦ - ៦០ ប្រកាស

អ្នកឧកញ៉ាទេស ទទួលបន្ទុកខាងក្រសួងអប់រំជាតិ

បានឃើញរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ,

បានឃើញព្រះរាជក្រឹត្យលេខ ១៨២ ក - ប - រ - ន ចុះថ្ងៃទី១៩ មេសា ១៩៦០ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រមលេខ ៣៨៣ ន. ស. ចុះថ្ងៃទី ២១ - ១១ - ៤៧ ហើយបានកែប្រែតាមព្រះរាជក្រមលេខ ៦១៩ ន. ស. ចុះថ្ងៃទី ២៣ - ១០ - ៥០ ស្តីពីការបង្កើតគណៈកម្មការមួយខាងការស្រាវជ្រាវ ហៅថា " គណៈកម្មការជាតិខាងអប់រំ " នៅទីស្តីការក្រសួងអប់រំជាតិក្រោមអធិបតីភាពនៃរដ្ឋមន្ត្រី ហើយនឹងព្រះរាជក្រមលេខ ៥០ ន. ស. ចុះថ្ងៃទី ២០ - ១០ - ៥៥ ដោយបានកែប្រែប្រាក់បំណាច់សរុប ដែលមានគ្រោងទុកក្នុងព្រះរាជក្រមទាំងពីរខាងលើនេះ ។

បានឃើញប្រកាសលេខ ៣២០៨ ចុះថ្ងៃទី ២៥ - ៩ - ៥៩ ស្តីពីការតែងតាំងគណៈកម្មការសម្រាប់ការសិក្សា( គណៈកម្មការរងទី១ សម្រាប់បឋមសិក្សាខ្មែរ ) ។

បានឃើញប្រកាសលេខ ១២៦០ ចុះថ្ងៃទី ១០ - ៥ - ៦០ ប្រគល់អំណាចដល់លោក កេនថាវជឺម៉ុងតឺរ៉ូ , រដ្ឋលេខាធិការក្រសួងអប់រំជាតិ ចំពោះការចុះហត្ថលេខាលើប្រកាសទាំងឡាយនៃទីស្តីការក្រសួងអប់រំជាតិ ។

បានឃើញសេចក្តីកត់ហេតុលេខ ៨៩ ចុះថ្ងៃទី ៩ មេសា ១៩៦០ (នៃគណៈកម្មការរងនៃបឋមសិក្សាខ្មែរ ) ។

តាមសេចក្តីស្នើសុំពីអគ្គនាយកសាធារណៈសិក្សា,

សម្រេច ៖

ប្រការ ១- សៀវភៅដែលមានចំណងជើង "សុភាវធម៌" របស់លោក ឈូក ម៉ឹង ម៉ៅ អធិការបឋមសិក្សាចាងហ្វាងក្រុមគរុកោសល្យបានបញ្ចូលទៅក្នុងពពួកសៀវភៅ និងការផ្សាយខាងការសិក្សាដែលនឹងបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងសាលាទូទៅក្នុងព្រះរាជាណាចក្រ ។

ប្រការ ២- នាយខុទ្ទកាល័យ និងអគ្គនាយកសាធារណៈសិក្សាត្រូវទទួលភារៈចាត់តាមមុខក្រសួងរៀងខ្លួន ដើម្បីឱ្យបានសម្រេចតាមប្រកាសនេះ ។

ភ្នំពេញ, នៅថ្ងៃទី ១ មិថុនា ១៩៦០

ជ. អ្នកឧកញ៉ាទេសរដ្ឋមន្ត្រី និង ត. ប.

រដ្ឋលេខាធិការក្រសួងអប់រំជាតិ

ហត្ថលេខា : កេនថាវដីម៉ុងតឺរ៉ូ

ចម្លងចែក

នាយកនៃបឋមសិក្សាសាធារណៈ

ហត្ថលេខា : ហួ - គីមស៊ីវ

ចម្លងចែក

ជ.អគ្គលេខាធិការនៃគណៈរដ្ឋមន្ត្រីនិង ត. ប.

ហត្ថលេខា : នួន - ច្រិក

# អំពីសុភាវធម៌ ឬ ភាពសមរម្យ

## ក្រឡេកមើលកម្មវិធីសិក្សាចាស់

ក្នុងកម្មវិធីសិក្សាចាស់-ត្រង់អន្លើដែលឥឡូវយើងហៅថា "សុភាវធម៌" មានចង្អុលឱ្យបង្រៀនអំពីចរិយាសាស្ត្រ ដូចជាមេរៀន អំពីសប្បុរសធម៌-ការគួរសម-សម្បជញ្ញៈ។ល។ ជាដើម។ គុណសម្បត្តិទាំងនោះសុទ្ធតែជាពាក្យអរូបពិបាកនឹងពន្យល់បាន។ ម្យ៉ាងទៀត ទោះបីក្មេងយល់ន័យពាក្យនេះហើយ ក៏នៅតែត្រឹមជាទ្រឹស្តីប៉ុណ្ណោះ មិនមែនជាបទឱ្យក្មេងប្រតិបត្តិតាមបានដោយងាយ..........

ក្មេងនៅតូចអាយុពី ៧ ទៅ ១៣ឆ្នាំ ត្រូវការឱ្យគ្រូណែនាំឱ្យមានទម្លាប់ល្អ ជាជាងចេះតែពាក្យហើយខ្វះការប្រតិបត្តិ។ ឧទាហរណ៍៖ ក្មេងទម្លាប់ល្អ បើវារើសបានរបស់អ្វីមួយ វាយកមកជូនលោកគ្រូ ថ្វីត្បិតតែវាមិនទាន់យល់ជាក់អំពីន័យនៃការលួច។ កុមារនេះត្រូវចាត់ទុកថា ជាកុមារប្រសើរជាងកុមារម្នាក់ទៀត ដែលចេះសូត្រមេរៀនប៉ោចៗអំពីទោសនៃការលួច តែបើវារើសបានវត្ថុអ្វីមួយ វាត្រឡប់ជាលាក់ទុកទៅវិញ ។

វិធីបង្រៀនឱ្យមានទម្លាប់ល្អទាំងនេះ នាំឱ្យមានកែកម្មវិធីជាថ្មី ហើយឱ្យឈ្មោះថា "សុភាវធម៌" : ភាពសមរម្យ ជាបទតូចជាងសុជីវធម៌ : ច្បាប់ជីវិតសមរម្យ ដែលសំរាប់និស្សិតនិងពលរដ្ឋធំៗ ។ សៀវភៅ "សុជីវធម៌" បានចាប់កំណើតអាស្រ័យហេតុដែលបានពោលរួចមកនៅខាងលើនេះឯង។

## វត្ថុបំណង

វិជ្ជា សុភាវធម៌ ជាចង្កោមក្បួនតម្រាទាំងឡាយដែលទម្លាប់កុមារឱ្យមានកាយវិការ និងសំដីសំដៅសមរម្យ ដើម្បីឱ្យការទាក់ទងរវាងកុមារនឹងអ្នកផងក្នុងសង្គម ប្រកបដោយសភាពស្រួលល្អ។

ត្រូវមានភារៈជួយឪពុក-ម្តាយកុមារក្នុងការបង្ហាត់បង្រៀនកុមារនោះឱ្យមានទម្លាប់ចេះសម្តែងអាការសមរម្យ ខាងកាយវិការនិងខាងវាចារ ។ ទម្លាប់ល្អនេះ កុមារកាន់ខ្ជាប់មួយជីវិត។

# កម្មវិធី

# សុភាវធម៌តាមកម្មវិធីថ្មី

កម្មវិធីខាងក្រោម ឥតហ៊ានអះអាងថា បានបង្ហាញគ្រប់នូវបទសុភាវធម៌ ដែលត្រូវបង្រៀនក្មេងនោះឡើយ។ លោកគ្រូ អាចស្រាវជ្រាវបទសុភាវធម៌ដទៃទៀត មកបង្រៀនក្មេងទៅតាមស្ថានការណ៍នៃជនបទ និងតាមកាលៈទេសៈ ។

១- <u>សុភាវធម៌នៅឯគេហស្ថាន</u>

- ជម្រាបសួរបិតា-មាតាយ៉ាងរីករាយនៅពេលភ្ញាក់ពីដំណេក - នៅពេលទៅសាលារៀន - នៅពេលមកពីរៀន - ត្រូវជម្រាបលោកមុននឹងទៅទទួលទានដំណេក ។

- ចំពោះមាតា-បិតាត្រូវសម្ដែងអាការៈ គួរសមទាំងកាយវិការ - ទាំងសំដីសំដៅ ។

- ទៅណាមកណា ត្រូវជម្រាបមាតាបិតាឱ្យជ្រាប ។

- យកអាសា(ជួយធ្វើការ) សមាជិកគ្រួសារគ្រប់ពេលវេលា ។

- បំបាត់អត្តទត្ថភាព(ការគិតដល់តែខ្លួនម្នាក់ឯងហួសប្រមាណ) ចេញពីខ្លួនដោយចៀសវាងប្រើអ្នកដទៃឱ្យធ្វើការអ្វីដែលខ្លួនអាចធ្វើខ្លួនឯងបាន ។

- ទុកដាក់វត្ថុផ្ទាល់ខ្លួនឱ្យត្រូវកន្លែង ។ កិច្ចនេះជាជំនួយជួយផ្ទះសម្ដែងឱ្យមានសណ្ដាប់ធ្នាប់ ។

- គេហដ្ឋានជាកន្លែងមួយគួរគោរព :

- ត្រូវជូតទ្រនាប់ជើង ឬ ជូតជើង។ ចំពោះក្មេងប្រុសត្រូវដោះមួកពេលណាត្រូវចូលក្នុងផ្ទះ ។

- មុននឹងចូលក្នុងផ្ទះ ត្រូវឱ្យដំណឹងដោយគោះទ្វារ

- ចេះដឹងទុក្ខធុរគ្នា និងរក្សាសភាពរីករាយរវាងបង-ប្អូនប្រុស-ស្រី ចៀសវាងការឈ្លោះប្រកែកគ្នា ។

- ចេះថា " អរគុណ " ចំពោះជនណាដែលធ្វើអំពើល្អ ឬអំពើមានប្រយោជន៍ដល់យើង។ បើយើងធ្វើអំពើមិនគប្បីត្រូវចេះនិយាយសុំទោស ។

២- <u>សុនាវ័ធមីចំពោះភ្ញៀវពន្លឺ</u>

- នៅចំពោះមុខភ្ញៀវ ត្រូវចេះប៉ាន់ តើពេលណាយើងគួរនិយាយ ពេលណាយើងគួរនៅស្ងៀម។
- ត្រូវចៀសវាងកុំនិយាយកាត់អ្នកណាដែលគេកំពុងនិយាយ ។ បើចាស់ទុំកំពុងនិយាយ យើងមិនត្រូវចូលចិត្តនិយាយជាមួយទេ បើគេមិនហៅយើងឱ្យនិយាយ ។
- បើមានភ្ញៀវមករក ចេះចេញទៅទទួលភ្ញៀវនៅឯមាត់ទ្វារ( ទ្វាររបង ឬទ្វារផ្ទះ ) ។
- រកកន្លែងដ៏គួរសមជូនភ្ញៀវពន្លឺអង្គុយ ។

៣- <u>សុនាវ័ធមីចំពោះអ្នកមកស៊ីឈ្នួលនៅធ្វើការក្នុងគ្រួសារយើង</u>

- ធ្វើចិត្តឱ្យល្អនិងមានសភាពរាបសារចំពោះអ្នកមកស៊ីឈ្នួល
- កុំបង្ខំប្រើគេទៅតាមទំនើងចិត្តសាវ៉ារបស់យើង ។ កុំឱ្យគ្នាសម្តែងការគោរពហួសហេតុពេកដែលជាអំពើអាម៉ាស់មុខគ្នា ។

៤- <u>សុនាវ័ធមីនៅពេលបរិភោគអាហារ</u>

- មកអាស្រ័យបាយឱ្យត្រូវទៅតាមពេលកម្រិត។ បើធ្វើបាន ត្រូវស្លៀតពាក់ដោយសមរម្យ។

- ការទទួលទានអាហារ ត្រូវប្រព្រឹត្តឡើងដោយស្អាតបាតនិងកុំឱ្យមានឮសូរ។ កុំប្រើស្ទន់ (ឈើចាក់ធ្មេញ )ក្នុងពេលបាយ ។ បើចៀសវាងមិនរួចសូមប្រើដោយលាក់លៀម ។ កុំបញ្ចេញអាការៈតាមសំដីតាមកាយវិការ ឬតាមរូបភាព ដែលជាហេតុនាំឱ្យគេល្ហើមនៅពេលបរិភោគ ។

- ឱ្យមានអង្គុយនឹងនួន សមរម្យ ហើយកុំចាកចេញពីកន្លែងបាយមុនគេ ដោយគ្មានពាក្យ "សុំទោស" ដោយគួរសម ។

៥- <u>សុនាវ័ធមីនៅសាលារៀន</u>

ក- <u>ចំពោះគ្រូបង្រៀន</u>

- មកសាលារៀនឱ្យទាន់ម៉ោង - ស្លៀកពាក់ឱ្យសមរម្យ - រាងកាយឱ្យស្អាតបាត។ ចំពោះនារីចៀសវាងនូវចំណាប់តាក់តែងកាយដោយហួសហេតុ ។

- ជំរាបសួរលោកគ្រូ កាលមកដល់សាលារៀន ជំរាបសួរលោកគ្រូកាលណាទៅផ្ទះ។ កុំចាកចេញពីកន្លែងអង្គុយដោយគ្មានសុំអនុញ្ញាតពីគ្រូ ។

- ជូនឬទទួលរបស់អ្វីមួយ ដោយដៃស្តាំ ។

- ក្រោកឈរ នៅពេលដែលមានភ្ញៀវកិត្តិយសមកដល់ថ្នាក់ ក្រោកឈរទៀត នៅពេលដែលភ្ញៀវនោះចេញទៅវិញ ។ កិច្ចនេះជាកិច្ចគោរពដល់ភ្ញៀវ សម្តែងការគោរពចំពោះភ្ញៀវនោះ ។

- បម្រុងខ្លួននិងជួយយកអាសារអ្នកផង ។ ដូចជា បើកទ្វារឱ្យ - ជូតកន្លែងឱ្យ ។ល។

- ទទួលបន្ទោស ហើយនិងទទួលការរំឭកពីលោកគ្រូ ដោយចិត្តស្រុះស្រួល ។

- សុំទោសលោកគ្រូបើកាលណាយើងភ្លេចគោរពប្រណិប័តន៍គាត់ ។

- ចេះសម្តែងការអរគុណចំពោះអ្នកណាម្នាក់ដែលបានយកអាសារយើង ។

- ការលើកដៃសំពះគោរព ត្រូវប្រព្រឹត្តឡើងដោយមានរបៀបរៀបរយ ។

ខ- ចំពោះមិត្តភ័ក្តិ

- យកអាសាមិត្តភ័ក្តដោយស្មោះស្ម័គ្រ ។

- ចៀសវាងការរំខានអ្នកផង នឹងទឹកមុខក្រញូវ ។

- បើមិត្តយើងមានជោគជ័យក្នុងការរៀនសូត្រ ត្រូវយើងចេះសរសើរ ដោយចិត្តស្មោះសរ។ ក្នុងល្បែងកីឡាក្តី - ក្នុងការរៀនសូត្រក្តី បើយើងចាញ់គេ ត្រូវទទួលភាពចាញ់នោះដោយសុទ្ធចិត្ត ។ ចៀសវាងការជម្លោះរវាងគ្នា ។

- ចៀសវាងកុំចំអកឡកឡឺយដល់ពិការភាពរបស់មិត្តយើង ។

- រវាងកុមារា - កុមារី ត្រូវចេះកាន់អាកប្បកិរិយាឱ្យសមរម្យ ។

៦- អាកប្បកិរិយាដែលត្រូវប្រព្រឹត្តនៅទីកន្លែងសាធារណ:

- គោរពច្បាប់ចរាចរណ៍ ។

- គោរពភ្នាក់ងារក្រុមនគរបាល ។

- ស្លៀកពាក់ឱ្យត្រឹមត្រូវនៅកន្លែងសាធារណៈ( កុំខ្លួនទទេ - កុំពាក់អាវភីសាមាឬសារុង ។

- កាន់អាកប្បកិរិយាថ្លៃថ្នូរ - កុំនិយាយឬសើចខ្លាំង - កុំប្រើពាក្យអាសអាភាស ។

- គោរពទីសាធារណៈ មិនត្រូវចោលសម្រាមលើស្មៅដាំ - មិនត្រូវបេះផ្កាឬផ្លែ នៅសួនសាធារណៈ និងចៀសវាងបត់ជើងតូច - បត់ជើងធំនៅទីនោះ ។

- ការស្តោះនិងកណ្តាស់ ជាបទរំខានដល់អ្នកផង ។ បើទប់មិនបាន ត្រូវធ្វើដោយលាក់លៀម។

- គោរពការរៀបរយ និងសភាពស្ងប់ស្ងាត់នៅទីសាធារណៈ ។

- ទៅទិញសំបុត្រចូលមើលទស្សនីយភាពផ្សេងៗ ទិញសំបុត្រជិះរថក្រុងឬទៅរកបង្គន់បត់ជើង ត្រូវឈរបន្តកន្ទុយគ្នាចាំដល់វេនយើង សឹមចូល។

- កាន់អាកប្បកិរិយាប្រកបដោយករុណាធម៌ ចំពោះទុក្ខវេទនាអ្នកដទៃ : ការគ្រោះថ្នាក់ - ក្បួនហែសព - ពិការភាព... ។ល។

- បញ្ជូនរបស់ដែលរើសបានទៅឱ្យភ្នាក់ងារទទួលខុសត្រូវ ឬទៅឱ្យម្ចាស់របស់វិញ ។

- ត្រូវបើកមួកសម្តែងសេចក្តីគោរព ចំពោះបុគ្គលដែលគួរគោរព ។

- នៅក្នុងរថក្រុង ជូនកន្លែងណាល្អដល់មនុស្សចាស់ - ដល់មនុស្សពិការ - ដល់ស្ត្រីមានផ្ទៃពោះ - កុំរំខានអ្នកជិតខាងដោយអង្គុយមិនដឹងខ្លួន និងដោយនិយាយខ្លាំងៗ ។

- ចេះអរគុណដល់អ្នកណា ដែលគេឱ្យកន្លែងមកយើង ។

- បើមានគេសួរព័ត៌មានណាមួយពីយើង ត្រូវឆ្លើយតបទៅគេដោយរាក់ទាក់ ។

- មិនត្រូវហួងហែងចិញ្ចើមវិថីឡើយ ។

- ជួយដឹកដៃក្មេង - ដឹកដៃមនុស្សចាស់នៅពេលឆ្លងវិថី ។

៧- <u>សុនាវ័ធម៌នៅពិធីបុណ្យសាសនា និងនៅវត្តអារាម</u>

- មិនត្រូវបង្កក្តីរីករាក្នុងបុណ្យ ។ គោរពទំនៀមទម្លាប់របៀបបុណ្យនោះ ។

- កុំបន្ថោកតម្លៃទីស្ថានដែលគេបូជា និងវត្ថុដែលគេគោរពតាមបទសាសនា ។

- ថ្វាយបង្គំព្រះសង្ឃទាំងកុមារ - កុមារីដោយមានរបៀបរៀបរយ ។

- ទៅវត្តអារាមដោយសម្លៀកបំពាក់ស្អាតបាតនិងសុភាពរាបស ។

៨- <u>សុនាវធម៌ចំពោះជនបរទេស</u>

៩<u>- យុវជនយើងនិងការសរសេរសំបុត្រ</u>

- សុភាវធម៌ក្នុងរបៀបធ្វើសំបុត្រ

- របៀបកាខ្ចងសំបុត្រ

គំរូស្រោមសំបុត្រ

## សេចក្ដីណែនាំជាផ្លូវគរុកោសល្យទូទៅ

ដូចបានឃើញស្រាប់ហើយពីខាងដើមនេះ គំនិត ក្នុងការអប់រំសិស្សខាងផ្នែកចរិយា ដែលមានក្នុងកម្មវិធីសិក្សាថ្មី សញ្ញាញដែលសម្ដែងក្នុងកម្មវិធីនោះសោតទៀត ក៏មានការប្រែប្រួលស្ទើរតែទាំងអស់ ។

ដូច្នេះវិធីបង្រៀននៃគ្រូ ក៏ត្រូវមានការប្រែប្រួលដោយច្រើនអន្លើដែរ ដូចជា ៖

១- ក្នុងកម្មវិធីថ្មីនេះ គ្មានការចែកមេរៀនជាឆ្នាំ - ជាត្រីមាស ឬ ជាខែទេ ។ លោកគ្រូ អ្នកគ្រូចង់លើកយកមេរៀនណាមួយមកសន្ទនាជាមួយសិស្សក៏យកចុះសុំតែឱ្យមេរៀននោះស្របនឹងវ័យសិស្ស - ស្របនឹងកាលៈទេសៈ - ស្របនឹងលក្ខណៈនៃសង្គមជុំវិញសាលារៀន ។

២- ក្នុងការសន្ទនានេះ សុំកុំឱ្យចាកឃ្លាតពីគំនិតមួយថា : សាលារៀនគ្មានការបង្ខំ - គ្មានការរិះគន់ដល់ជនណា - ដល់គ្រួសារណា ដល់សង្គមណា ។ សាលារៀនមានតែការស្នើ : ស្នើផ្ទាល់នឹងសិស្ស ដើម្បីយកយោបល់ពីសិស្ស និងឱ្យមានការអនុវត្តន៍តាម - ស្នើដល់មាតាបិតាសិស្ស ដើម្បីនឹងឱ្យមាតាបិតានោះ ជួយតម្រែតម្រង់ចរិយាសិស្សនៅក្នុងគ្រួសារផង ។

៣- មិនមែនតែក្នុងពេលដែលសម្ដែងពីសុភាវធម៌ទេ ដែលគ្រូអាចនិយាយពីសុភាវធម៌បាន ។ កាលណាកាលៈទេសៈហុចឱ្យហើយ គប្បីគ្រូមានការរំឭកដាស់តឿនសិស្សភ្លាម ដូចជា : ស្លៀកពាក់មិនតាមបែបបទជាសិស្ស - សំពះមិនសមភ្នែក - ខាកស្ដោះក្នុងបន្ទប់រៀន ឬ តាមបង្អួច - បេះផ្កានៅសួនសាលា ។ល។

៤- ការបង្រៀនរបៀបនេះ មិនសមលោកគ្រូដាក់មេទន្ទេញឱ្យសិស្សសូត្រចាំមាត់ដូចកាលដើមឡើយ ព្រោះលទ្ធផលបានល្អឬពុំបានល្អ មិនមែនសន្ធត់ត្រង់ សិស្សចាំមេរៀនឬមិនចាំទេ គឺស្រេចនៅលើការសង្កេតនៃគ្រូចំពោះភាពសមរម្យសិស្ស តើបានចម្រើន ឬនៅតែដដែល ឬមួយថយក្រោយទៅវិញ ។

៥- យើងសុំបង្ហាញមធ្យោបាយខ្លះ សម្រាប់ពិសោធន៍នូវចរិយាសិស្ស ដូចមានខាងក្រោមនេះ ៖

ក- នៅក្នុងបន្ទប់រៀន គួរមានប្រអប់ចំហរមួយតូចល្មម នៅពីមុខសិស្សដោយមានស្លាកបិទពីលើថា " របស់រើសបាន " នេះជាមធ្យោបាយសម្រាប់ពិសោធន៍ សុចរិតធម៌នៃសិស្ស - បង្ហាញថាកុមារមិនគប្បីគៃបំបាត់របស់គេ រើសបានរបស់គេមិនលាក់ទុកជារបស់ផ្ទាល់ខ្លួន ។

ខ- គួរឱ្យមានរបស់មួយទៀត មានប្រហោងអាចឱ្យបញ្ចូលសំបុត្របានហៅថា ៖ "ប្រអប់សំបុត្រស្នើ " ។ គ្រូណែនាំសិស្សឱ្យមានការស្នើពីហេតុផ្សេងៗ ដែលមានកើតឡើងនៅក្នុងសាលាឬក្រៅសាលា - ក្នុងការអប់រំឬក្រៅការអប់រំ អ្វីជាប្រយោជន៍ទូទៅ...... សេចក្ដីស្នើណាដែរមានសមហេតុសមផលឬដែលមាន សិស្ស

ភាគច្រើនស្មើ គួរគ្រូយកមកពិគ្រោះគ្នាជាមួយនឹងសិស្ស ។ សេចក្ដីខ្លះជាអាថ៌កំបាំង ជាចំណុចផ្ទាល់របស់សិស្សម្នាក់ គួរគ្រូមានការពិគ្រោះផ្ទាល់នឹងសិស្សនោះម្នាក់ឯង ។

គ- គួរដាក់នៅទ្វារចូលបន្ទប់រៀន ទ្រនាប់មួយសម្រាប់ជូតជើង ឬទ្រនាប់ស្បែកជើង ធ្វើពីកៅស៊ូ ជក់ដូង ហើយសិស្សនឹងគ្រូអាចធ្វើបាននៅពេលបង្រៀនម្ដងៗ ។ នេះជាមធ្យោបាយមួយសម្រាប់ បញ្ជាក់ក្មេងពីគំនិតថា : បន្ទប់រៀនឬផ្ទះ - ឬកុដិ - ព្រះវិហារជាទីដែលយើងគួរគោរព មុននឹងយើងចូល យើងគួរក្រឡេកមើលជើង ឬទ្រនាប់ជើងយើងសិន ។ ណែនាំសិស្សឱ្យមានទម្លាប់មួយយ៉ាងប្រសើរ នាំឱ្យកាយវិការនេះយូរទៅ ធ្វើឡើងដោយឯងៗ ។

ឃ- នៅកៀនមួយនៃបន្ទប់រៀន គួរមានដាក់កញ្ចក់មួយសម្រាប់ឱ្យសិស្សឆ្លុះមើលម្ដងៗ តើមុខមាត់ សក់ក្បាល មានអ្វីត្រង់ណា មិនសមនឹងភ្នែកអ្នកជិតខាងឬទេ ។

ង- តាមវិធីអប់រំរបៀបក្រុមកាយរឹទ្ធិ គេបញ្ញត្តឱ្យក្រុមកាយរឹទ្ធិម្នាក់ៗ សម្ដែងនៅមុខក្រុមគេ នូវអំពើណាដែលជាប្រសើរ ហើយដែលគេបានប្រព្រឹត្តក្នុងមួយថ្ងៃៗ ។ គប្បីគ្រូណែនាំសិស្សក្នុងថ្នាក់ទាំងអស់ ឱ្យមានសៀវភៅម្នាក់មួយ - ម្នាក់មួយ សម្រាប់ឱ្យសិស្សកត់ត្រាអំពីបែបនេះ បើមិនបានរាល់ថ្ងៃ ក៏បានពីរ-បីថ្ងៃម្ដង ឬមួយសប្ដាហ៍ម្ដង ជាការបញ្ជាក់ដល់សិស្សនូវសេចក្ដីចម្រើននៃសិស្សត្រង់ផ្នែកចរិយា ។

ច- នៅទីធ្លាគប្បីមានធុងសម្រាមមួយដែលសិស្សអាចធ្វើបាន ។ណែនាំសិស្សឱ្យមានទម្លាប់មួយទៀតយ៉ាងប្រសើរ គឺមិនចោលសម្រាម ក្រដាស់ឥតសណ្ដាប់ធ្នាប់ នាំឱ្យមានការលំបាកបោសសំអាតបន្ទប់រៀន ទីធ្លា និងផ្ទះសំបែង ។ ហើយបើម្នាក់ៗមានទម្លាប់បែបនេះ ឃើញថា ការថែទាំទីលំនៅពុំសូវឱ្យមាន ការរវល់ច្រើន ។

ឆ- តាមផ្លូវចេញចូលក្នុងសាលារៀន នៅចំណតទោចក្រយាន ក្នុងសាលាគួរដាក់សញ្ញាខ្លះរបៀបដូចជាសញ្ញាចរាចរ ដែលក្រសួងសាធារណៈការ ដាក់តាមវិថីក្រុង ដើម្បីបង្ហាញថា វិថីនេះរថយន្តអាចទៅមុខបាន - វិថីនេះទៅពុំបាន ទីនេះជាចំណតរថយន្ត ទីនេះហាមមិនឱ្យរថយន្តចត ។ល។ នេះមិនមែនគ្រាន់តែណែនាំឱ្យមានរបៀបរៀបរយក្នុងសាលារៀនទេ គឺជាមធ្យោបាយមួយទៀត សម្រាប់ទម្លាប់កុមារា - កុមារីឱ្យចេះដើរ ឱ្យចេះជិះកង់ នៅក្នុងទីក្រុង ចៀសវាងកុំឱ្យមានគ្រោះថ្នាក់ផងទៀត ។

---

## វត្ថុបំណងរបស់សៀវភៅនេះ

សៀវភៅសុភាវធម៌នេះ មានបំណងចង់ធ្វើសេចក្ដីអធិប្បាយនូវកម្មវិធីសិក្សាខាងលើឱ្យបានក្បោះក្បាយ ជួយវែកញែកហេតុផលសុភាវធម៌ - ជួយចង្អុលមូលដ្ឋានសុភាវធម៌ - ជួយណែនាំរបៀបសុជីវធម៌តាមខ្មែរនិយម និងតាមបរទេសនិយមខ្លះ ដើម្បីជាគ្រឿងជំនួយដល់គ្រូ អ្នកបង្រៀនក្មេង ។

សៀវភៅនេះឥតមានបំណងថា ជាក្បួនជាក់លាក់ដាច់ខាតនៃសុភាវធម៌ទេ ព្រោះតាមសេចក្ដីយល់របស់យើង សង្គមខ្មែរដែលកំពង់តែវិវត្តន៍ មិនអាចឱ្យយើងចងបទបញ្ញាសុភាវធម៌បានឡើយ ព្រោះសុភាវធម៌នេះឯងកំពុងតែវិវត្តន៍ធ្វើដំណើរទៅជាមួយនឹងសង្គមដែរ ។

ម៉្យាងទៀងដោយយល់ថាសុភាវធម៌មានបទប្លែកៗគ្នា តាមតំបន់ជនបទតាមទំនៀមទម្លាប់ តាមជំនឿសាសនា តាមវណ្ណៈ។ល។ សៀវភៅយើងនេះ និយាយបានតែបែបជាឧរាល់ទូទៅ ។ អន្លើណាដែលយល់ថាល្មមប្រតិបត្តិបាន សូមប្រតិបត្តិតាមចុះ អន្លើណាដែលយល់ថា បើប្រតិបត្តិទៅហើយត្រឡប់ជាឆ្គងទៅវិញនោះ សូមកុំអាលប្រតិបត្តិឬកុំប្រតិបត្តិតាមតែម្ដង ។

រួមសេចក្ដីសៀវភៅយើង មានវត្ថុបំណងជាសៀវភៅល្បង ជាសៀវភៅណែនាំ មិនមែនជាសៀវភៅ បទបញ្ញាតឹងរឹងនោះទេ ។

## ការទស្សនៈអំពីសុភាវធម៌

ហេតុដែលនាំឱ្យមានសុភាវធម៌ មកតែអំពីធម្មជាតិមនុស្ស ដែលកើតមកហើយត្រូវតែរស់ក្នុងសង្គម ជាមួយនឹងមនុស្សឯទៀត កណ្តាលធម្មជាតិដ៏ធំធេងនេះ ។

ម្ល៉ោះហើយត្រូវមានការទាក់ទង រវាងមនុស្សនឹងមនុស្ស រវាងមនុស្សនឹងធម្មជាតិ ការទាក់ទងនេះនាំឱ្យមនុស្ស សិក្សាស្គាល់អាត្មាខ្លួនឱ្យច្បាស់ម្លោះហើយទៅជាមានបទទាក់ទង មនុស្សនឹងអាត្មាខ្លួនទៀត ។

ការទាក់ទងនេះបើប្រព្រឹត្តឡើងដោយមិនមានភាពសមរម្យ និស្ស័យដូចដុំកង់ដែលវិលដោយគ្មានប្រេង រមែងមានការទង្គិច ការសៅហ្មងជានិច្ច ។

សុភាវធម៌មិនមែនជាបទអនាម័យ មិនទាន់ជាចរិយាសាស្ត្រខ្ពស់ៗនោះទេ គ្រាន់តែជារបៀបរៀបសារមនុស្សឱ្យមានការសមរម្យខ្លះ សមនឹងភ្នែក សមនឹងត្រចៀក សមនឹងទំនៀមទម្លាប់អ្នកផង ដែលយើងត្រូវរស់ជាមួយដើម្បីចៀសវាងកុំឱ្យមានការទាស់ភ្នែក ទាស់ត្រចៀក និងការទង្គិចរវាងមនុស្សដែលរស់នៅក្នុងសង្គមជាមួយគ្នា ។ ឧទាហរណ៍ ៖ សន្មត់ថាមនុស្សម្នាក់ ជាអ្នកគ្មានបដិបត្តសាសនាទេ ដល់មនុស្សនោះទៅក្នុងចំណោមដែលគេសូត្រធម៌ទាំងអស់គ្នា ច្បាប់សុភាវធម៌ បង្គាប់មនុស្សនោះឱ្យរៀនសូត្រធម៌នឹងគេដែរ( ចូលស្ទឹងតាមបទ )…. គួរដាក់ខ្លួនឱ្យចូលចុះជាមួយគ្រប់ចំណោមមនុស្ស - កុំនៅស្ងៀមប្លែកពីគេទោះការដែលគេកំពុងធ្វើនោះខុសនឹងទំនៀមទម្លាប់ ឬចំណូលចិត្តយើងក៏ដោយ ។

មូលដ្ឋានមួយបែបទៀតដែលនាំឱ្យមានសុភាវធម៌ ព្រោះធម្មជាតិមនុស្សជាសត្វខ្ពស់ ជាសត្វមានសប្បជញ្ញៈ ជាសត្វមានសន្ទុះទៅរកសីលធម៌ ជាសត្វមានមនោសញ្ចេតនា ដែលជុះខាត់ឱ្យកាន់តែល្អិត ឱ្យកាន់តែថ្លាណាស់ទៅទៀតមិនឈប់ មិនឈរ ។

លក្ខណៈសម្បត្តិនៃមនុស្សទាំងប៉ុន្មាននេះឯង ដែលជាមូលដ្ឋានឱ្យមនុស្សបង្កើតសុភាវធម៌ គឺរៀបចំទាក់ទងគ្នាឱ្យខុសពីការទាក់ទងរវាងសត្វនឹងសត្វ ហើយឱ្យចេះតែមានការជឿនលឿនទៅមុខជាដរាប ។ យើងអាចសង្កេតឃើញថា ក្នុងសង្គមមនុស្សដែលអារ្យធម៌ទន់ទាបនៅឡើយ ដែលសប្បជញ្ញៈនៅស្លូចស្តើងនៅឡើយ សុភាវធម៌ក៏គ្រោតគ្រាត ។ ដល់សង្គមកាន់តែចម្រើនទៅ អារ្យធម៌កាន់តែខ្ពស់ សម្បជញ្ញៈកាន់តែជុះដាល សុភាវធម៌ក៏កាន់តែចម្រើន មិនកើតឯងៗដោយគ្មានមូលដ្ឋាននោះទេ សុភាវធម៌ជាប់ទៅនឹងការវិវត្តន៍របស់សង្គមមនុស្ស ។

សង្គមខ្មែរចាកភាពទាសភាពហើយ សង្គមខ្មែរយើងកំពុងតែវិវត្តន៍ទៅកាន់ក្តីចម្រើន ទៅកាន់ភាពខ្ពស់ ដូច្នេះយើងគួរតែនាំគ្នាសិក្សារឿងសុភាវធម៌ឱ្យស្របទៅតាមដំណើរនៃសង្គមយើង ។

## សេចក្តីសង្កេត

សេចក្តីសង្កេតខាងលើនេះ នាំសៀវភៅយើងឱ្យចាកឃ្លាតអំពីវង្វង់សាលាបឋមសិក្សាខ្លះហើយ ដែលសេចក្តីទាំងនោះមានសារៈសំខាន់សម្រាប់បញ្ជាក់នូវមូលដ្ឋាន សុភាវធម៌មានគ្រឹះរឹងប៉ឹង កុំឱ្យគ្រាន់តែជាផ្សែងបក់ទៅដោយខ្យល់ជំនោរម្តងៗ ។

# លំនាំដើម

មុននឹងអធិប្បាយនូវមេរៀនដោយចំពោះ យើងសូមបញ្ជាក់គោលការណ៍ខ្លះដូចតទៅនេះ បទរៀនអំពីសុភាវធម៌នេះសំដៅដល់សិស្ស អាយុពី ៧ ទៅ ១៣ឆ្នាំ គឺថាសិស្សនេះជាតួសំខាន់នៃសៀវភៅយើង ។ ពោលម្យ៉ាងទៀត គឺយើងនិយាយអំពីសុភាវធម៌ ភាពសមរម្យដែលសិស្សស្រី - ប្រុសអាយុពី ៧ ដល់ ១៣ឆ្នាំ ត្រូវប្រតិបត្ត មិនមែនសំដៅមនុស្សចាស់ពេញវ័យនោះទេ ។

ស្គាល់តួសំខាន់ហើយ ទើបយើងវែកញែករកមជ្ឈដ្ឋាន រកចំណោមមនុស្សឯទៀត ដែលទាក់ទងជាមួយនឹងតួសំខាន់សិស្សយើងនេះ ។ គេអាចចែកតាមលំដាប់ដូច្នេះក៏បានគឺ ៖

១- សិស្ស នឹងធម្មជាតិ ទេសភាព - ផ្ទះសំបែង - សត្វពាហនៈ និងសត្វឯទៀត

២- សិស្សនឹងចំណោមមនុស្សឯទៀត ឪពុកម្តាយ - ចាស់ព្រឹទ្ធាចារ្យ - គ្រូបង្រៀន - មិត្តរបស់វា - បាវព្រាវ

៣- សិស្សនឹងអាត្មាខ្លួនវា រាងកាយ - សំលៀកបំពាក់ - មនោសញ្ចេតនា - សំដីសំដៅ - គំនិត

តែក្នុងសៀវភៅយើងនេះ យើងមិនសរសេរតាមលំនាំខាងលើនេះទេ យើងសរសេរតាមលំនាំដែលបានតែងតាមកម្មវិធីវិញ ដូចសេចក្តីអត្ថាធិប្បាយតទៅនេះ ៖

# ជំពូកទី ១

# សុភាវធម៌នៅឯគេហដ្ឋាន



# មេរៀនទី ១ - គេហដ្ឋាន

ឆាពសមរម្យនៅផ្ទះ

គេហដ្ឋាននេះសំដៅ គេហដ្ឋានដែលមានន័យធ្លាយទូលាយ មិនមែនគ្រាន់តែផ្ទះស្លឹក ឈើឬស៊ីម៉ង់ត៍ជាម្លប់ជ្រកកោនប៉ុណ្ណោះទេ គឺសំដៅគេហដ្ឋានខាងផ្លូវសម្ភារៈ ខាងផ្លូវចិត្តផង ។

<u>ខាងផ្លូវសម្ភារៈ</u> ផ្ទះជាអាគារមួយ ដែលកុមារកើតមកហើយបានជ្រកកោន បានរស់នៅទីនោះ ។ ភ្នែកកុមារបានឃើញគេហដ្ឋានជាលើដំបូង បានចាប់អារម្មណ៍ឃើញថា ទីនេះអញបានស្រួល អញបានសប្បាយ អញបានរស់ធំ ។

<u>ខាងផ្លូវចិត្ត</u> ផ្ទះជាកន្លែងដែលជាប់ចិត្ត ដែលមានទម្លាប់នៅទីនោះនាំឱ្យរឭក នាំឱ្យស្រលាញ់ហើយនាំឱ្យគោរព ។ ផ្ទះខ្មែរខ្លះ មានរៀបតាំងអាសនៈព្រះពុទ្ធ ដែលមានព្រះពុទ្ធរូប ជួនកាលថូផ្កា ជួនកាលមានភ្លើងធូប ឬ ភ្លើងប្រទីបអុជឆេះជាអលជ្ជី ។

គេហដ្ឋានដំបូងជាទីជ្រកកោន រួចមកជាទីស្រលាញ់ រហូតដល់ជាទីគោរព ។

អារ្យធម៌អឺរ៉ុបនិយមទុកគេហដ្ឋាននេះ ជាទីជាប់ចិត្តដ៏ក្រៃលែង ។ ពាក្យគេហដ្ឋាន អង្រួនសន្ដានចិត្តគេ ស្មើនឹងពាក្យអនុស្សាវរីយ៍ក្រុមញាតិ ។

ម៉្យាងទៀត របៀបអប់រំ គេលៃលកឱ្យកូននីមួយៗ មានបន្ទប់មួយម្នាក់ដែលវាអាចរៀបចំទុកដាក់ទៅតាមចិត្ត ទៅតាមរស ទៅតាមគំនិតរបស់វា ។ បន្ទប់នេះជាសញ្ញាតម្លៃផ្ទាល់ខ្លួនរបស់វា ដែលជារូបនិម្មិតនៃចារឹកចរិយា ឧត្តមគតិ និងបុគ្គលិកលក្ខណៈរបស់វា ។

សិស្សគប្បីយល់ជម្រៅគេហដ្ឋានទៅតាមន័យដែលបានអធិប្បាយខាងលើនេះ ។

# មេរៀនទី ២ - កូននិងឪពុក - ម្ដាយ

នៅក្នុងផ្ទះ មានឪពុក-ម្ដាយ ជាមេជាអ្នកធំ ។ ចំពោះឪពុក-ម្ដាយ កូនត្រូវមានសុភាវធម៌យ៉ាងណាខ្លះ ?

ជាកិច្ចឧរាល់ទូទៅ កូនត្រូវស្រលាញ់ឪពុក-ម្ដាយ ។ ស្រលាញ់ហើយត្រូវគោរពលោកទាំងពីរទៀត" ដូច្នេះ បើឪពុក-ម្ដាយហៅ ត្រូវឆ្លើយ "បាទឬចាស" ហើយរត់មកឥតលាក់លាមដោយញញឹមញញែមហើយ ចាំស្ដាប់គាត់មានប្រសាសន៍ រួចធ្វើតាមបង្គាប់គាត់ដោយទឹកមុខស្រស់ ។

ត្រូវប្រុងស្ដាប់ឪពុក-ម្ដាយ ហើយធ្វើតាមបង្គាប់គាត់ដោយញញឹម ។

ហៅមិនឆ្លើយឬហៅមិនមក មកហើយមិនធ្វើតាម ឬធ្វើតាមដោយ ទឹកមុខក្រញូវជាទំនាស់ នឹងសុភាវធម៌ ។

ការចេះលៃឱ្យមានការទាក់ទងរវាងកូន និងឪពុក-ម្ដាយ ដោយសំដី - ដោយកាយវិការខ្លះ តាមពេលដែលធ្វើបានមិនងប់ជ្រុលច្រើនពេក ឬតិចពេក ទុកជាភាពសមរម្យមួយ ក្នុងគ្រួសារទំនើបដែលគេឱ្យឈ្មោះថា "សុភមង្គលក្នុងគ្រួសារ " ។

## មេរៀនទី ៣ - គោរពនិងបំរើឪពុក - ម្តាយ

កូនគប្បីមកជម្រាបសួរឪពុក-ម្តាយ ដោយធ្វើកាយវិការសំពះសួរ នៅពេលដែលភ្ញាក់ពីដំណេក - មុនពេលទៅសាលារៀន នៅពេលដែលត្រឡប់មកពីសាលារៀនវិញ នឹងនៅពេលទៅចូលដំណេក កូនអាចនិយាយថា៖ "លោកប៉ា អ្នកម៉ាក់ខ្ញុំភ្ញាក់ពីគេងហើយ ខ្ញុំទៅរៀនហើយ! ខ្ញុំមកពីសាលាវិញហើយ! ខ្ញុំទៅគេងហើយ! ។ ឪពុក-ម្តាយក៏គួររកពាក្យឆ្លើយសំដៅទៅកូនវិញ៖

"កូនគេងស្រួលទេ កូនទៅរៀនហើយ ទៅសាលាខំរៀនណាកូន! កូនរៀនបានលេខល្អទេ ទៅគេងឆាប់លក់ណាកូន! "

នៅប្រទេសអឺរ៉ុប មានបារាំងសេស មានអង់គ្លេសជាដើម កិច្ចនេះកូននឹងម្តាយឪពុក ប្រព្រឹត្តជារាល់ពេល ។ តាមទំនៀមគេ ឪពុកម្តាយថើបកូន កូនថើបឪពុកម្តាយ ។

នៅប្រទេសអាស៊ីខ្លះ ដូចជាប្រទេសជប៉ុន កូនមកគោរពឪពុកម្តាយដោយធ្វើកាយវិការងក់ក្បាល ។ តាមតំបន់ជនបទ តាមកាលៈទេសៈ តាមឋានៈគ្រួសារ តើខ្មែរយើងត្រូវចាប់ប្រតិបត្តិយ៉ាងណា ការគោរពនិងការស្រលាញ់ឪពុកម្តាយ ត្រូវសម្តែងចេញតាមកាយវិការ និងតាមពាក្យសំដី រាល់ពេលវេលាដែលគួរធ្វើបាន។

ពេលឪពុកម្តាយត្រូវការប្រើបន្តិចបន្តួច :

ហុចផ្តិល ហុចក្រមា យកឈើគូស យកកាសែត ។

ពេលឪពុកម្តាយមានភ្ញៀវ បើលោកឱ្យគោរពភ្ញៀវ គោងធ្វើតាមភ្លាម បើលោកឱ្យអង្គុយជិត ឬឱ្យទៅលេងឆ្ងាយ ក៏ត្រូវតែធ្វើតាមដោយទឹកមុខរីករាយ ។

## មេរៀនទី ៤ - ទៅណាមកណា ជម្រាប ឪពុក - ម្តាយ

កាលណារកកូនមិនឃើញ ឪពុកម្តាយតែងមានក្តីបារម្ភណ៍ជានិច្ច ដូច្នេះមុននឹងទៅណាមកណាកូនត្រូវជម្រាបឪពុក-ម្តាយឱ្យលោកជ្រាប ។ បើលោកមិនឱ្យទៅហើយយើងនៅតែចង់ទៅ ត្រូវរកពាក្យពន្យល់ដោយការ

គួរសមឱ្យលោកស្តាប់បាន ជម្រាបលោកពីដំណើរដែលយើងទៅ ទៅទីណា ជួបនរណា ពេលណាមកវិញ ហើយមានផលប្រយោជន៍យ៉ាងណា ។ កូនដែលធ្វើឱ្យឪពុក-ម្តាយព្រួយ ដោយសារពីរឿងទៅណាមកណាមិនប្រាប់ ពីរឿងមានជំងឺហើយមិនប្រាប់ ទុកជាខុសបទសុភាវធម៌ដែរ ត្រង់អន្លើដែលកូនបានធ្វើអំពើជាហេតុនាំឱ្យឪពុក-ម្តាយមិនសប្បាយ ។

តាមទំនៀមទម្លាប់ខ្មែរពីរឿងទៅបាត់ពីផ្ទះគ្មានដំណឹងនេះ ចំពោះកូនស្រីជារឿងនាំឱ្យឪពុក-ម្តាយព្រួយខ្លាំងទៅទៀត ។

ជាបទនិទាន : ចំពោះក្មេងអាមេរិកាំង បើបាត់ពីផ្ទះឪពុក-ម្តាយម៉ែនឹកភ្លាមថា មានពួកចោរចាប់កូនដើម្បីឱ្យម្តាយឪពុកយកលុយទៅលោះដោយស្ងាត់ ។ ចំពោះក្មេងជប៉ុន ឪពុក-ម្តាយភ័យពីរឿងបាត់កូនក្នុងគ្រោះថ្នាក់ ព្យុះ ឬរញ្ជួយផែនដី ។ ចំពោះកូនខ្មែរ ពីដើមឪពុក-ម្តាយភ័យរឿងប្រមាត់ប្រមង់ចាប់ រឿងនេះជារឿងមិនពិតទេ ឥឡូវនៅទីក្រុងធំៗ ឪពុក-ម្តាយភ័យអំពីគ្រោះថ្នាក់ចរាចរណ៍ លង់ទឹក ឆ្កែឆ្កួតខាំ ។

# មេរៀនទី ៨ - ជួយធ្វើការនៅផ្ទះ

នៅក្នុងផ្ទះដដែលរមែងមានការធ្វើបន្តិចបន្តួចជានិច្ច ។ កូនក្មេងត្រូវជួយធ្វើការនោះ ដោយមិនមើលបំណាំ បងប្អូនឯទៀតនឹងអ្នកនៅជាមួយ ការនោះមានដូចជា៖ ស្រូចផ្កា បោសទីធ្លាផ្ទះ រៀបតុបាយ។ល។

គ្រួសារទំនើបខ្លះ មេផ្ទះចែកការដល់កូនឱ្យដាច់មុខពីគ្នា នេះជាការប្រសើរមួយបែបដែរ ឧទាហរណ៍៖ បងស្រីដាំបបរ ប្អូនស្រោចផ្កា ប្អូនឯទៀតបោសជណ្តើរ ឬជូតបង្អួច ជូតតុទូ ជាដើម ។

មានពេលខ្លះបងប្អូនមានធុរៈបំពេញការរបស់ខ្លួនមិនបាន ក្មេងជាបទសុភាវធម៌ ត្រូវជួយបងប្អូននោះផង។ វិធីនេះជាមធ្យោបាយដឹកនាំសិស្សកុំឱ្យមានអត្តទត្ថភាព គឺគិតតែខ្លួនឯងឱ្យបានស្រួលជាងគេ ។

ផ្ទុយទៅវិញនាំសិស្សឱ្យមានចិត្តជួយរំលែកការគេទៅទៀតដោយទឹកមុខរីករាយ ។

# មេរៀនទី ៦ - សណ្តាប់ធ្នាប់ក្នុងគេហដ្ឋាន

នៅក្នុងផ្ទះរមែងមានការរៀបចំឱ្យសមសួន ជាកន្លែងទទួលភ្ញៀវ ជាបន្ទប់សម្រាប់ដេក ជាជើងក្រាន ។ល។ រៀបនេះនាំឱ្យវត្ថុនីមួយៗ មានកន្លែងច្បាស់របស់វា ចានដាក់ដោយចាន វែកដាក់ដោយវែក ក្រមាដោយក្រមា ។ បើក្មេងយករបស់អ្វីមួយមកប្រើប្រាស់ ប្រើរួចហើយត្រូវយកទៅដាក់កន្លែងវាវិញកុំឱ្យគេពិបាករក ។

ម្យ៉ាងទៀតម្នាក់ៗត្រូវជួយរៀបចំផ្ទះឱ្យមានសណ្តាប់ធ្នាប់ ឃើញទាស់ភ្នែកហើយកុំដើរហួស ។ រឿងសិស្សនិងរបស់របនេះ អាចមធ្យោបាយទៅខាងផ្លូវមនោសញ្ចេតនា ខ្លះជាប់ចិត្តយ៉ាងខ្លាំងលើរបស់នេះ ហើយត្រូវដាក់កន្លែងនោះ ។ ក្មេងមិនត្រូវទៅបង្វិតរបស់គេឱ្យខុសកន្លែងចំណាំរបស់គេឡើយ ។ មិនតែប៉ុណ្ណោះបើមានឱកាសធ្វើបាន គួររករបស់ដែលបងប្អូនស្រលាញ់ផ្តល់ឱ្យបងប្អូនផង ។ ឧទាហរណ៍ ៖ បើបងស្រីយើងស្រលាញ់ផ្កាកុលាប បើយើងបានផ្កាកុលាប គួរយកទៅឱ្យបងយើងដើម្បីបងយើងបានសប្បាយ ។

# មេរៀនទី ៧ - កិច្ចចំពោះគេហដ្ឋាន

យើងបានឱ្យន័យពីគេហស្ថានរួចម្តងហើយ ឥឡូវនេះអាស្រ័យទៅតាមន័យនោះ ក្មេងត្រូវគោរពគេហស្ថាន ។ គេហស្ថានត្រូវរៀបឱ្យស្អាតដូច្នេះត្រូវជួយបណ្តុះ ជួយតាក់តែងឱ្យល្អ ។ មុននឹងឡើងផ្ទះត្រូវជូតជើងឱ្យស្អាត ដោះស្បែកជើង បើទំនងត្រូវឱ្យដោះ ដូចជាទំនៀមនៅស្រុកជប៉ុន ទំនៀមនៅវត្ត ។ ក្មេងប្រុសត្រូវដោះមួកជាការគួរសម ពេលចូលដល់ផ្ទះ ដាក់ភាពក្រៅឱ្យសមរម្យ សំដីសំដៅឱ្យសមរម្យ ។ រឿងជំរៅជាងនេះទៅទៀតគឺចេះនាំក្មេងឱ្យដាក់ចិត្តថា វានៅចំពោះមុខផ្ទះគេមួយ ដែលជាទីសុខសាន្ត ជាព្រលឹងរបស់គ្រួសារគេ ។

ទោសដែលក្មេងមិនគោរពផ្ទះមានដូចតទៅ ៖

- បង្ហើរខ្លែងមកទើរលើដំបូលផ្ទះគេ
- បាញ់គ្រាប់ចំពាមកៅស៊ូឱ្យត្រូវផ្ទះគេ
- ដើរបេះបោចផ្លែឈើក្នុងរបងផ្ទះគេ ។ល។

## មេរៀនទី ៨ - ឱ្យដំណឹងមុននឹងចូលទៅកន្លែងណា

មកដល់មាត់ទ្វារផ្ទះគេហើយ ធ្វើឱ្យគេដឹងសិន ៖ តាមការស្រែកហៅដោយទន់ភ្លន់ លោកអ៊ុំម្ចាស់ផ្ទះនៅឬទេ? តាមការគោះទ្វាររបៀបទំនើប ។ យ៉ាងណាក៏មិនត្រូវចូលស្ងាត់ៗឱ្យសោះ ។

ទោសនៃការចូលផ្ទះគេដោយម្ចាស់ផ្ទះគេមិនដឹង នាំឱ្យគេកើតមន្ទិលសង្ស័យក៏មាន តែសំខាន់បំផុតគឺយើងអាចទៅវាក់នឹងការផ្ទាល់ខ្លួនរបស់គ្រួសារគេ ។

ស្រែកសួរគេហើយឬគោះទ្វារហើយចាំស្តាប់គេឱ្យដំណឹង តើគេឱ្យចាំបន្តិចឬគេឱ្យចូលភ្លាម ។

រឿងនេះមានសារៈសំខាន់ចំពោះការិយាល័យនៃអ្នកធំ ។ ដល់ចូលទៅហើយក្មេងត្រូវកាន់អាកប្បកិរិយាតាមសភាពផ្ទះគេទៀត : អង្គុយកន្លែងឱ្យសមរម្យ អង្គុយបែបដូចម្តេច(លើកៅអី - លើក្តារដើ ឬលើរនាប) ។

បើលើផ្ទះគេឃើញមានការទាស់ភ្នែក យើងកុំនិយាយហើយមើលចិត្តអ្នកម្ចាស់ផ្ទះ ពេលណាដែលយើងត្រូវលាចេញមកវិញ ។ នៅផ្ទះគេកុំយូរពេក កុំឆាប់ពេក មើលអធ្យាស្រ័យគេផង មើលក្រែងយើងរំខានគេ ដោយគេមានរវល់ផង ។

## មេរៀនទី ៩ - រវាងបងប្អូនប្រុស-ស្រី

រវាងបងប្អូនប្រុសនិងស្រី ក្មេងត្រូវរក្សាឫកពាររីករាយនឹងគ្នា គឺត្រូវចៀសវាង ៖

- ធ្វើទឹកមុខក្រញូវ ចងចិញ្ចើម អង្គុយធ្មឹង សួរមួយមាត់ និយាយមួយមាត់

- រំខានបងប្អូនដោយកាយវិការ ដោយប្រើសំដីមិនសមរម្យ

- មានចិត្តឈ្នានីស មិនចង់ឱ្យបងប្អូនសប្បាយជាង ឬស្រួលជាង ច្រណែនចាក់រុក ផ្ទុយទៅវិញ ត្រូវបង្កើតឱ្យមានបរិយាកាសរីករាយដោយ ៖

- ធ្វើទឹកមុខស្រស់ញញឹម, ធ្វើកាយវិការសមរម្យ ចំពោះបងប្អូនប្រុសស្រីប្រើសំដីទន់ភ្លន់មិនមែនមាយា

- ដោយជួយយកអាសារបងប្អូន តាំងពីបំរើហុចនេះហុចនោះបន្តិចបន្តួចរហូតធ្វើឱ្យបងប្អូនបានសប្បាយដោយសារ មានពេលខ្លះជួយលាក់កំហុសបងប្អូនក៏សឹងបាន ។

- វាងផ្លូវចិត្ត មិនប្រចាំគ្នា មិនច្រណែនគ្នា មិនចាក់រុកគ្នា ។ បងប្អូនប្រុសចំពោះបងប្អូនស្រី ត្រូវចៀសវាងកាយវិការណានិងសំដីសំដៅណាជំទាស់នឹងការអៀនខ្មាស់ ចំពោះវាងភេទនឹងភេទ ។

- ចំពោះបងប្អូនស្រី និយាយនឹងធ្វើកាយវិការសន្ទនា ដែលយើងរីករាយនឹងការធ្វើនោះ ចំពោះមុខម្តាយឪពុក ។

## មេរៀនទី ១០ - រៀនឱ្យចេះថា " អរគុណ "

ដើម្បីឱ្យការទាក់ទងមានទំនងល្អ ត្រូវទម្លាប់ប្រើពាក្យ " អរគុណ " ពាក្យអរគុណនេះ យើងថានៅពេលដែល ៖

- អ្នកម្នាក់ទៀតបានធ្វើអំពើអ្វីជាប្រយោជន៍ដល់យើង អ្នកម្នាក់ទៀតជួយយកអាសាយើងតាមបែបបទណាមួយ ។

ពាក្យថា "អរគុណ" នេះជាសេចក្តីខ្លីដែលមានលក្ខណៈស្និទ្ធស្នាលខ្លះៗ

- កូនសិស្សចំពោះគ្រូត្រូវថា: អរគុណលោកគ្រូ អរគុណអ្នកគ្រូ !

ចំពោះមិត្តសិស្សខ្មែរអាចថា : អរគុណណាស់បង !

បើរឿងយកអាសានេះជារឿងធំ សិស្សត្រូវថា : ខ្ញុំសូមអរគុណ......ដ៏ជ្រាលជ្រៅ ដោយលោកឬអ្នកបាន......! (ទៅតាមអំពើដែលគេបានធ្វើ ) ។

គេអាចតបនឹងពាក្យ "អរគុណ" វិញ នៅពេលខ្លះនឹងចំពោះមនុស្សបានដូចតទៅ ៖

- មិនជាការធ្ងន់ស្រាលប៉ុន្មានទេ !
- ជាការធម្មតាទេ !
- មិនដឹងជាចាំបាច់អរគុណអ្វីទេ ការប៉ុណ្ណឹង!

តាមវិធីសុភាវធម៌នៅឯគេហស្ថានចប់តែប៉ុណ្ណោះឯង ។ តែគ្រូ បើឃើញសេចក្តីអត្ថាធិប្បាយនេះខ្វះដោយអន្លើខ្លះ អាចបំពេញបានតាមការគួរ ។

# ជំពូកទី២

# សុភាវធម៌ចំពោះភ្លៀវពន្លឺ



# មេរៀនទី ១១ - អ្វីហៅថាភ្ញៀវ

ភ្ញៀវពន្លឺសំដៅញាតិឆ្ងាយជិត អ្នកនៅជិតខាង អ្នកនៅភូមិជាមួយឬអ្នកដទៃសោះដែលមកផ្ទះយើង ដើម្បីមកលេង សួរសុខទុក្ខ ឬមួយមានការទាក់ទងក្នុងការចិញ្ចឹមជីវិត ឬមួយមកសំណាក់ជារយៈក្នុងការធ្វើដំណើរទៅណាមកណា ។

ជាតិខ្មែរមានលក្ខណសម្បត្តិមួយពីបុរាណកាលមក ជាអ្នកចេះទទួលភ្ញៀវដោយស្មោះសរ ។ គេតែងសង្កេតឃើញថា ខ្មែរតែងយកសម្ភារៈល្អៗ សម្រាប់ទទួលភ្ញៀវ ។

ផ្តិល ប៉ាន់តែ ចានក្បាន រហូតម្ហូបអាហារក៏សុទ្ធតែសម្រាំងឱ្យបានល្អជាងធម្មតា............ ភស្តុតាងធំៗជាងនេះទៅទៀត គឺនៅប្រទេសខ្មែរ ក្នុងតំបន់ជនបទណាក៏ដោយរមែងមានសង់សាលាសំណាក់ ទុកសម្រាប់អ្នកដំណើរស្នាក់ នៅមុខផ្ទះខ្លះមានពាងទឹកដំកល់ជូនអ្នកដំណើរអាស្រ័យ លក្ខណៈទាំងនេះ គប្បីយើងដឹងហើយរក្សាទុកដោយរៀបចំទៅតាមដំណើរស្រុកទេសទៅមុខ ។

# មេរៀនទី ១២ - ពេលភ្ញៀវមកដល់

បើភ្ញៀវមកដល់ផ្ទះយើង កុមារជាបទសុភាវធម៌ មានករណីយកិច្ចបំពេញច្រើនណាស់ ដំបូងអាចស្រែកជំរាបឪពុកម្តាយថា ៖

"លោកអុំ-លោកពូ-អ្នកមីង អញ្ជើញមកហើយ" បើផ្ទះយើងមានឆ្កែព្រុះ ត្រូវបង្ក្រាបសត្វនោះកុំឱ្យរំខានដល់ភ្ញៀវ រួចស្ទុះទៅបើកទ្វារភូមិដោយប្រើវាចារថា ៖

"លោកអុំ-លោកពូ-អ្នកមីង អញ្ជើញឡើងលើផ្ទះ" ។ បើភ្ញៀវមានឥវ៉ាន់ជាទម្ងន់យួរ ត្រូវសុំជួយកាន់ ។

នៅស្រុកស្រែអាចជួយដោះរទេះ ជួយចងទូក ។

ដល់ភ្ញៀវឡើងដល់លើផ្ទះហើយ តាមបង្គាប់ឪពុកម្តាយ ត្រូវធ្វើពិធីជំរាបសួរដោយទឹកមុខញញឹម ហើយឆ្លើយតបសំនួរភ្ញៀវដោយក្បោះក្បាយ តាមធម្មតានិងទៅតាមឋានៈភ្ញៀវ ត្រូវមានដាក់ស្លា ម្លូ បារី ទឹកតែ ទឹកត្រជាក់ទឹកកក រហូតដល់ភេសជ្ជៈផ្សេងៗ ទៀតក៏សឹងមាន ។

បើឪពុកម្ដាយរវល់មិនទាន់ចេញមកបាន កុមារត្រូវចេះនិយាយសុំទោសភ្ញៀវជួសឪពុកម្ដាយយើង ។ ជាការកែអផ្សុកអាចយកទស្សនាវដ្ដី សៀវភៅរូបកាសែត ជូនភ្ញៀវមើលនឹងអានកំសាន្ត ។ កុមារត្រូវអង្គុយកំដរលុះត្រាតែឪពុកម្ដាយមកដល់ ។

ដល់ឪពុកម្ដាយមកហើយ ស្ទង់ឃើញថាយើងគ្មានហេតុផលអ្វីនឹងនៅទីនេះទេ ទើបថយទៅនៅជិតបម្រុងខ្លួនក្រែងឪពុកម្ដាយនឹងភ្ញៀវមានការទាក់ទងរកហៅ ។

បើភ្ញៀវមានកូនក្មេងអាយុដំណាលនឹងយើងឬតូចជាងយើង ត្រូវចេះនាំក្មេងនោះទៅលេងជាមួយនឹងយើងផង មើលរូបសៀវភៅ លេងបាយឡុកបាយឡ ។

បើសិនជាហេតុការណ៍ត្រូវឱ្យកុមារនោះនៅជាមួយនឹងភ្ញៀវ ត្រូវចេះនិយាយតបឆ្លើយឱ្យសមរម្យគឺថាពេលសមនិយាយ សឹមនិយាយ កុំនិយាយតែឯង កុំបញ្ចេញអំនួត ពេលគួរស្ងៀមសត្រូវចេះស្ងៀម កុំស្ងៀមទ្រមឹងមិចេះនិយាយ ។

ការនិយាយត្រូវនិយាយសម្របទៅតាមរឿងរបស់ភ្ញៀវ ចៀសវាងបង្កើបរឿងណាដែលជាទំនាស់នឹងសន្តានចិត្តភ្ញៀវ ។ ការចេះសន្ទនាជាមួយភ្ញៀវទុកជាវិជ្ជាដ៏កម្រមួយ ត្រូវការចេះលៃសំដី ចេះរករឿងនិយាយ ចេះស្ដាប់ ចេះលួងលោមភ្ញៀវ គឺថាប្រើរបៀបមួយរយដំពូកដើម្បីឱ្យភ្ញៀវរីករាយជានិច្ច ។

អក្សរសាស្ត្រខ្មែរយើង មានក្បួនមួយឈ្មោះ "ក្បាច់ស្រី" ដែលចែងអំពីភ្ញៀវដូចតទៅ ៖

"ក្រមួយមិនបានសំដី ពាក្យទន់តិចន័យ ឱ្យញាតិចូលចិត្ត ក្រមួយមិនចេះរិះគិត ឃើញញាតិឆ្ងាយជិតហៅឡើងផឹស្លា ... ។

## មេរៀនទី ១៣ - ចេះគោរពឡៀវ

តាមលំនាំធម្មតាចាស់ៗ ជួបគ្នាច្រើនដំណាលអំពីកូនចៅ ។ ឪពុកម្ដាយយើង អាចយកយើងទៅបង្ហាញដល់ភ្ញៀវ ដោយដាក់ឫកពាឈរឬអង្គុយឱ្យសមរម្យ

- ធ្វើតាមចិត្តភ្ញៀវសុំឱ្យធ្វើ ដូចជាមើលសាត្រាជំនាន់ដើម ដូចជាច្រៀងតាមទំនុកដែលរៀននៅសាលាឬសម្ដែងរបាំតាមរៀនឯសាលាក៏សឹងមាន ។

ក្រៅពីនោះអាចមានការបង្ហាញសៀវភៅសរសេរ គំនូរឬជាស្នាដៃខាងការហត្ថកម្មណាមួយ ។ ពេលនោះត្រូវរក្សាស្មារតីឱ្យនឹងនួន កុំសម្តែងចំណោះហួសហេតុ ឬអឹមអៀនលាក់មុខមិនបានការ នាំឱ្យបាក់មុខមាតាបិតា ។ ចៀសវាងដាច់ខាតកុំនិយាយចែចូវពីកេរ្តិ៍ខ្មាសសាលា កេរ្តិ៍ខ្មាសគ្រូ ឬកេរ្តិ៍ខ្មាសមិត្តណាមួយប្រាប់ភ្ញៀវ ។

## មេរៀនទី ១៨ - ក្មេងរំខានភ្ញៀវ

ទោសនៃក្មេងដែលរំខានភ្ញៀវរមែងមានដូចតទៅ ៖

- ភ្ញៀវមកដល់នៅលេងធម្មតា ព្រងើយកន្តើយដូចគ្មាននរណាមក មិនរវល់អើពើនឹងភ្ញៀវដល់តិចតួចសោះ
- ចំអកឡកឡឺយឱ្យភ្ញៀវដោយឃើញការមិនគួរបែបណាមួយរបស់ភ្ញៀវ
- ពេលភ្ញៀវនិយាយ ខ្លួនក៏តាំងនិយាយខ្លាំងៗដែរ ឬប្រទ្បែងគ្នារត់កាត់ចំពោះមុខភ្ញៀវ
- លំអុកដាក់ម្តាយឪពុកទារស៊ី ឬទារលុយ គឺឆ្លៀតឱកាសដែលម្តាយឪពុកជាប់ដៃជាមួយនឹងភ្ញៀវ

រឹងរូសមិនធ្វើតាមបង្គាប់ឪពុកម្តាយនៅមុខភ្ញៀវ ឬមិនធ្វើតាមបង្គាប់ភ្ញៀវ....។ បទទាំងនេះត្រូវចៀសវាងដោយដាច់ខាត ។

## មេរៀនទី ១៩ - ជូនដំណើរភ្ញៀវ

ពេលដែលភ្ញៀវទៅវិញ របៀបប្រហែលៗ នឹងពេលដែលភ្ញៀវមកដល់ត្រូវកុមារប្រុងចាំប្រតិបត្តិឡើងដូចជា ៖

- មកសំពះគោរពលាភ្ញៀវ
- ចាំបម្រុងគ្រួតឆ្កែកុំឱ្យវាព្រុះ ឬវារំខានភ្ញៀវពេលភ្ញៀវចុះពីផ្ទះ
- បម្រុងបើកទ្វាររបងពេលភ្ញៀវចេញ ពេលយប់បំភ្លឺផ្លូវចេញ

- កុំប្រញាប់បិទទ្វារ លត់ភ្លើង ឬសំដែងអាការៈណាមួយថា យើងទន្ទឹងឱ្យតែភ្ញៀវចុះឆាប់ ។ សំខាន់បំផុត កុំធ្វើទឹកមុខ ឬបន្លឺសម្លេងជាសញ្ញាថា យើងបានធុញនឹងភ្ញៀវនោះ ។

សុភាវធម៌ទំនើប អាចណែនាំឱ្យបងប្អូនប្រជុំគ្នាដេញដោលគ្នារកការសម ឬមិនសម ។ រំឭកគ្នា បើអ្នកណាម្នាក់ឃើញថា មានការទាស់ឆ្គងចំពោះភ្ញៀវ ដើម្បីកែរបៀបកែទៅថ្ងៃក្រោយ ។

រឿងសុភាវធម៌ចំពោះភ្ញៀវសន្មតថាចប់តែប៉ុណ្ណោះ តែគ្រូអាចបង្កើតរឿងវែកញែកឆ្ងាយទូលាយចំពោះភ្ញៀវ ទៅតាមឋានៈជាអ្នកមាន ជាអ្នកក្រ ជាពាស្ត្រ ជានាម៉ឺន ជាសង្ឃ ជារាជវង្ស ជាជាតិបរទេស ជាអ្នកមានសាសនាខុសគ្នា ។

# ជំពូកទី ៣

# សុភាពធម៌ចំពោះអ្នកមកស៊ីឈ្នួល
# នៅធ្វើការក្នុងគ្រួសារយើង



# មេរៀនទី ១៦ - មនុស្សនៅបំរើ

មនុស្សកើតមកហើយមានតម្លៃស្មើៗគ្នា ។ តែមានមនុស្សខ្លះនៅបំរើដោយការទីទាល់ក្រ និងដោយគ្មានចំណេះ យកកម្លាំងមកដូរយកឈ្នួល ។ របរនេះឥតបន្ថយតម្លៃមនុស្សឡើយ ។ នៅអារ្យប្រទេស និងនៅគ្រួសារមានច្បាប់ទម្លាប់ ឈ្នួលបម្រើធ្វើការមានម៉ោងពេល មានពេលត្រូវសម្រាកដូចតែភ្នាក់ងារអ្នកធ្វើការផងទាំងឡាយ ។ នៅជានីធំៗខ្លះ នៅចន្លោះពេលរៀនមាននិស្សិតមហាវិទ្យាល័យជាច្រើនទៅស៊ីឈ្នួលលាងចានជូតស្បែកជើង បម្រើកាហ្វេ មើលក្មេង ឃ្វាលចៀមនឹងគោ ។ល។ ហេតុផលទាំងនេះបញ្ជាក់ថា មុខការស៊ីឈ្នួលឥតត្រូវចាត់ទុកថាជាថោកទាបឡើយ ។ ឥឡូវនេះនៅរាជធានីយើងចាប់មានកូនសិស្សនៅវិទ្យាល័យឆ្លៀតរករបររត់ស៊ីក្លូ លក់នំប៉ុង ឈូសឈើ លក់ទឹកទៅហើយដែរ..... ។

នេះបញ្ជាក់មួយអន្លើទៀតថា ការលក់កម្លាំងយកឈ្នួលឥតទៅបន្ថយតម្លៃមនុស្សឡើយ ។

ការយល់ជាក់នូវតម្លៃមនុស្សដូច្នេះនាំឱ្យក្មេងយល់ករណីយកិច្ចខ្លួន ចំពោះមនុស្សស៊ីឈ្នួល ។

# មេរៀនទី ១៧ - មានចិត្តប្រពៃដល់អ្នកបំរើ

ចំពោះមនុស្សស៊ីឈ្នួលក្នុងគ្រួសារយើង កុមារត្រូវប្រុងប្រយ័ត្នរក្សាបទសុភាវធម៌ឱ្យខ្ជាប់ខ្ជួន ដំបូងត្រូវកុំមានចិត្តយល់ថាពួកនោះជាមនុស្សថោកទាប ហើយក៏តាំងចិត្តមើលងាយ ។

ផ្ទុយទៅវិញកុមារត្រូវតាំងចិត្តជាដើមអាទិថា : ពួនោះជាអ្នកកំសត់ទុរគត មករួមរស់ជាមួយនឹងគ្រួសារយើង មាននាទីជាអ្នកធ្វើការហត្ថកម្ម ជាអ្នកហត់ច្រើនជាអ្នកប្រើកម្លាំងកាយសុទ្ធៗ ។

អាស្រ័យហេតុនេះ កុមារត្រូវមានសប្បុរធម៌ ចិត្តល្អប្រពៃដែលត្រូវសំដែងចេញដោយសំដីវាចា( ហៅ ពូ-មីង-បង តាមអាយុ កុំហៅ ហង-អា-មឹង ដោយដាច់សាច់ ) ដោយកាយវិការ( កុំធ្វើកាយវិការមាក់ងាយ ) និងដោយគំនិត( កុំប្រើហួសហេតុ ) ។

លើសពីមានចិត្តសប្បុរសធម៌ កុមារត្រូវមានការគួរសមទៀត : គួរសមខាងផ្លូវអាការៈ ខាងវាចា ខាងកាយវិការ និងខាងទឹកចិត្តទៀត ។

# មេរៀនទី ១៨ - កុំប្រើឈ្នួលខុសសណ្ដាប់ធ្នាប់

ក្នុងការប្រើឱ្យធ្វើការឱ្យយើង ត្រូវចៀសវាងកុំប្រើគ្នាច្រងាប់ច្រងិលខុសពេលវេលាពេក ដោយមិនលៃទៅតាមកាលនិងកម្លាំង គឺទៅតាមទំនើងចិត្តក្មេងដែលមិនសូវសមហេតុផល ។

ម្យ៉ាងទៀត ត្រូវចៀសវាងបង្ខំអ្នកស៊ីឈ្នួលយើងឱ្យសម្ដែងការគោរពចំពោះយើង ដែលជាបទបន្ទាបបន្ថោកតម្លៃមនុស្ស ។ រួមសេចក្ដី កុមារត្រូវចាំក្នុងចិត្តថា យើងត្រូវរក្សាចិត្តល្អ ការគួរសមចំពោះមនុស្សមកស៊ីឈ្នួលក្នុងផ្ទះយើង ។

# ជំពូកទី ៤

# សុភាពធម៌នៅពេលបរិភោគ



# មេរៀនទី ១៩ - ការបរិភោគអាហារ

ការបរិភោគអាហារ ជាឱកាសមួយដែលអាចសម្គាល់បានថាកុមារចេះសុភាវធម៌របៀបបរិភោគអាហារ។

ការបរិភោគអាហារនេះ គឺមានសភាពនិងទំនៀមទម្លាប់ប្លែកៗគ្នាទៅតាមគ្រួសារមាន - ក្រ ឬមធ្យមទៅតាមសាសន៍ជាតិ ចិន - បារាំង - ឥណ្ឌា - យៀកណាម - ខ្មែរ និងទៅតាមកាលៈទេសៈ បរិភោគធម្មតាក្នុងគ្រួសារ ពេលបុណ្យទាន ពេលមានភ្ញៀវពន្លឺ ឬពិធីជប់លៀងធំៗ ។

គោលធំពីរដែលប្លែកគ្នាដាច់ស្រឡះ គឺរបៀបអាស៊ី និងអឺរ៉ុប :

អឺរ៉ុបមានម្ហូប-ចាន-កែវ-សម-ស្លាបព្រា ដាច់ស្រឡះពីគ្នា ឥតមានយកសម-ស្លាបព្រាយើងទៅដួសសម្លក្នុងចានលាយឡំនឹងគេទេ ។

អាស៊ីមានម្ហូបជាមួយគ្នាដែលអ្នកបរិភោគអាហារអាចយកស្លាបព្រា-សមទៅដួសលាយឡំគ្នាបាន ។

សម័យថ្មីនេះនៅប្រទេសខ្លះ មានជប៉ុន-ហ្វីលីពីន-ប្រទេសថៃជាដើម គេចាប់និយមបំបែកមុខម្ហូបឱ្យដាច់ពីគ្នា គឺថាម្នាក់ៗ មានចានគ្រប់ម្ហូបរៀងៗខ្លួន មិនលូកជាមួយគ្នាក្នុងចានតែមួយទៀត ។

រឿងចែកម្ហូបដាច់ពីគ្នានេះ ប្រព្រឹត្តឡើងដោយផ្អួលទៅតាមច្បាប់អនាម័យ ។ រឿងនេះជារឿងងាយយល់ទេ ។

តទៅនេះយើងនឹងបរិយាយអំពីសុភាវធម៌ក្នុងពេលអាស្រ័យបាយ ពេលប្រក្រតី ។

## មេរៀនទី ២០ - មុនពេលបាយ...

ពេលបរិភោគអាហារសុទ្ធសឹងតែបានកម្រិតម៉ោងស្រេច ម្ល៉ោះហើយកុមារត្រូវមកឱ្យត្រូវពេលវេលាកុំឱ្យឪពុកនឹងអ្នកផងចាំខ្លួន ។ នៅគ្រួសារខ្មែរធម្មតាកុមារត្រូវជួយរៀបបាយ មានការក្រាលកន្ទេលឬរៀបតុ លើកទឹក ជូតចាន ជូតកែវជាដើម ។ កិច្ចនេះត្រូវធ្វើដោយទឹកមុខរីករាយ តែសំខាន់បំផុតដោយស្អាតបាត ហើយដោយប្រុងប្រយ័ត្នកុំឱ្យមានការថ្លស់ការ : បែកកែវ បែកចាន ។ បើលៃធ្វើបាន ពេលអាស្រ័យអាហារគប្បីស្លៀកពាក់ឱ្យសមរម្យដោយនឹកក្នុងចិត្តថា កុំឱ្យខ្លួនយើងជារូបភាពដែលគេអាល្អើមបាន( ញើស-ខ្លួនទទេឬមានក្រមាមិនស្អាត ) ។

មកដល់ឃើញម្ហូបហើយ ចៀសវាងសម្ដែងអាការៈឃ្លានជ្រុល ឬផ្អុយទៅវិញ ធ្វើទឹកមុខសោះអង្គើយពេក ។ កុមារបើមេផ្ទះមិនបានចង្អុលកន្លែងឱ្យអង្គុយទេ ត្រូវលៃមើលកន្លែងណាដែលសមនឹងខ្លួនអង្គុយ គឺកន្លែងមិនផុចជិតចាស់ពេក មិនបាំងភ្លើងឬបាំងពន្លឺ ។ បើអង្គុយផ្ទាល់នឹងរនាបគប្បីអង្គុយបត់ជើងតាមទំនៀមខ្មែរ ។ បើគេអនុញ្ញាតឱ្យបញ្ឈរជង្គង់ឬពែនភ្នែន ត្រូវប្រព្រឹត្តឡើងដោយរម្យទម ដាក់ដៃឱ្យសមកុំច្រងែងច្រងាង ។ បើយើងដួសបាយឱ្យគេជាលើកដំបូង កុំដួសតិចពេក តែត្រូវចៀសវាងដួសហៀរចានដែរ ហើយដួសជូនចាស់មុនជាលំដាប់មក ។

## មេរៀនទី ២១ - របៀបបរិភោគ

វិធីបរិភោគដោយចំពោះតែម្ដង ត្រូវចាំទុកក្បួនសំខាន់មួយ គឺះ បរិភោគកុំឱ្យឮ ហុតសម្លកុំឱ្យឮគ្រូក គឺកុំបឺត កុំស្រូប កុំព្រួស តែត្រូវហាមាត់ ភ្លើយកបន្តិចស្មើរតែយកស្លាបព្រាដួសទឹកសម្លចាក់ទៅក្នុងមាត់ គឺចៀសវាង

កុំឱ្យស្លាបព្រាប៉ះចាន - ប៉ះធ្មេញ ។ ទំពាម្ហូបរឹងកុំឱ្យឮសូរ គឺត្រូវទំពារថ្នមៗ កុំបន្លឺសម្លេងដើម្បីសម្ដែងសេចក្ដីឆ្ងាញ់ ឬការហឺរជ្រុល ។ កុំឆ្លៀតនិយាយពេលម្ហូបនៅក្នុងមាត់ ។ ចៀសវាងកុំសើច ភ្ញើកឬភើ ។

របៀបខ្មែរបរិភោគឱ្យអស់ពីចាន ។ គេតែងនិយមថា " កុំបរិភោគឱ្យឆ្អែតពេក គឺលៃឱ្យនៅឃ្លានបន្តិចពេលដែលឈប់បរិភោគហើយ ..។

## មេរៀនទី ២២ - កំពុងបរិភោគ

វិធីលូកម្ហូបក៏ត្រូវឱ្យមានសុភាវធម៌ខ្ពង់ខ្ពស់ដែរ គឺចៀសវាងកុំលូកតែម្ហូបណាដែលឆ្ងាញ់ជាងគេ លៃលូកម្ហូបឱ្យស្មើមុខគ្នា តែបើមានចានឆ្ងាយពីយើងពេក ក៏មិនត្រូវឈោងទៅលូកដែរ ។ ពេលកំពុងបរិភោគគេអាចសួរយោបល់យើងពីម្ហូបអាហារ យើងគប្បីឆ្លើយថាឆ្ងាញ់ពិសារណាស់ ។ ត្រូវលៃបញ្ចប់ការបរិភោគជាមួយនឹងអ្នកផងឯទៀត កុំឈប់មុនគេពេក កុំឈប់ក្រោយគេពេក។ បើឈប់មុនគេ ហើយត្រូវការក្រោកចេញពីវង់បាយត្រូវនិយាយសុំទោសគេដោយទន់ភ្លន់ ។

គោលការណ៍ដែលត្រូវចាំមួយទៀត គឺនៅពេលបរិភោគ ចៀសវាងនិយាយបញ្ចេញសម្លេង ឬសម្ដែងអាការៈណាមួយដែលនាំឱ្យគេល្ហើម ។

ការប្រើស្ទន់(ឈើចាក់ធ្មេញ) បើចៀសវាងបាន ត្រូវចៀសវាង ។ បើត្រូវតែប្រើដោយខានមិនបាន ត្រូវយកដៃម្ខាងបាំងមាត់ ធ្វើដោយលាក់លៀម ដោយរហ័ស ហើយលាក់ស្ទន់នោះឱ្យបាត់ភ្លាម ។

## មេរៀនទី ២៣ - បរិភោគតាមរបៀបទំនើប

ក្នុងគ្រួសារទំនើបដែលការបរិភោគប្រព្រឹត្តឡើងនៅលើតុនោះ នឹងមានបទសុភាវធម៌ផ្សេងៗទៀត ដូចជា៖ របៀបអង្គុយលើកៅអី ត្រូវទាញកៅអីកុំឱ្យឮ បើមានស្រី ត្រូវយើងទាញកៅអីឱ្យស្រីអង្គុយមុន ។ ពេលអង្គុយ អង្គុយឱ្យត្រង់ខ្លួន កុំផ្អែកទៅលើកៅអីពេក កុំពិតទៅលើតុពេក កុំកន្ទែកជើងជ្រុល គងដៃទៅលើតុឱ្យល្មម ហើយឱ្យចេះប្រើដៃទាំងពីរ ។ ត្រូវចេះប្រើកន្សែង ត្រូវចេះកាន់ស្លាបព្រា សម កាំបិត កុំឱ្យធ្លង ។ បើមានការនិយាយ កុំធ្លាដៃ-ធ្លាជើង ។

**ពាក្យបុរាណ.....ខ្លះ!**

សុភាវធម៌ដែលបានចែងមកនេះ និយាយតែជាឱវាល់ទូទៅឥតសម្តែងដល់ពិធីដប់លៀងធំៗនោះទេ ។ មុននឹងបញ្ចប់ជំពូកនេះ ត្រូវរំឭកសុភាសិតខ្មែរខ្លះដូចតទៅ ៖

"បើស៊ី កុំតាមឃ្លាន គិតប្រមាណដល់គ្នីគ្នា"

"បើស៊ីចង់ពិសា ខ្ជិលទំពាឱ្យហ្មត់ហ្មង"

អាចនិទានរឿងព្រេង ដូចរឿង "ធនញ្ជ័យ និងសម្លមីសួរ" ហើយនឹងរឿង "លោកសង្ឃនឹងផែនដីក្រឡាប់" ឱ្យសិស្សស្តាប់ក៏បាន ។

# ជំពូកទី ៥

# សុភាពធម៌នៅសាលារៀន



# មេរៀនទី ២៨ - បញ្ញាឯកសណ្ឋានសិស្ស

រឿងនេះជារឿងរបស់សិស្សដោយចំពោះ ។ ដូច្នេះគួរតែយើងលាតត្រដាងបញ្ហាខ្លះនៃរឿងសិស្សានុសិស្ស ។

សិស្សានុសិស្សជាសង្គមកុមារកុមារីមួយ ដែលមានសារៈក្នុងសង្គមជាតិ អ្នកផងឃើញកូនសិស្សអាចវិនិច្ឆ័យថា សង្គមនោះបានទៅកាន់សេចក្ដីចម្រើនដល់ណាហើយ ។

ប្រទេសខ្លះរៀបចំកូនសិស្សឱ្យមានសំលៀកបំពាក់ជាឯកសណ្ឋានដូចៗគ្នា ដោយគេចង់ឱ្យកូនសិស្សមានសភាពខាងក្រៅដូចៗគ្នា កុំឱ្យឆ្លុះឃើញថា មានអ្នកមាន អ្នកក្រពេក ។ ម្យ៉ាងទៀត ស្លៀកឯកសណ្ឋាននាំឱ្យល្អមើលផង ហើយទម្លាប់ក្មេងឱ្យចេះថែទាំសំលៀកបំពាក់ ឱ្យចេះអ៊ុតស្អាត ឱ្យមានចងបូរ ពាក់មួក សំពត់ខ្លី និងស្បែកជើង ស្រោមជើងដូចៗគ្នា ។ របៀបស្លៀកពាក់ជាឯសណ្ឋាន នាំឱ្យសិស្សមានគំនិតជាសង្គមជាមួយ

គ្នា ថែមទាំងចេះរក្សាកិត្តិយសដែលជាប់នឹងឯកសណ្ឋាននោះព្រោះ ឯកសណ្ឋានរមែងមានរូបសញ្ញានាម សាលានៅជាមួយផង ។

## មេរៀនទី ២៥ - សំលៀកបំពាក់សិស្ស

ប្រទេសខ្លះចោទថា ឱ្យសិស្សស្លៀកឯកសណ្ឋានជារបៀបទាហាននិយមពេក ។ គេបណ្ដោយឱ្យសិស្សស្លៀកបានតាមចិត្ត តែគង់គេណែនាំឱ្យកាត់សក់មានរបៀប ។ ចំពោះក្មេងស្រីកុំឱ្យពាក់អាវស្ដើងចេញសាច់ កុំឱ្យពាក់អលង្ការ មាសពេជ្រជាដើម កុំឱ្យប្រើទឹកអប់ធុនថ្លៃ កុំឱ្យលាបបបូរមាត់ ។

គេហាមប្រាមមិនឱ្យស្លៀកពាក់បែបនេះ ដើម្បីជាបទអប់រំក្មេងស្រី ឱ្យមានភាពជាសិស្សកុមារីសមរម្យ មិនមែនស្រីពេញរូបរាង ។ ដូច្នេះមានថែមការអប់រំតាំងពីដំណើរ ទឹកមុខ ការធ្វើកាយវិការ ។

ប្រទេសខ្លះ ហាមមិនឱ្យកាត់អាវមានរាង បញ្ចេញរាងភេទស្រីឬអាវមានកធំបញ្ចេញសាច់ គឺចៀសវាងរបៀបស្លៀកពាក់ ដែលជាហេតុនាំឱ្យមានក្ដីសម្រើបសម្រាល ។

ខ្មែរយើងគួរបញ្ជាក់របៀបនេះ តាមបែបបទណាមួយ ។

## មេរៀនទី ២៦ - មកសាលាឱ្យទាន់ម៉ោង

សុភាវធម៌នៃសិស្សចំពោះសាលា ដែលត្រូវកត់ចំណាំឱ្យជាក់ជាងគេនោះគឺ សិស្សត្រូវមកសាលាឱ្យទាន់ពេលវេលា ។ តាមធម្មតា សាលារៀនបង្ហាញពេលវេលាតាមសូរកណ្ដឹង ឬសូរស្គរពីរដង ដងដំបូង សម្រាប់ឱ្យដំណឹងដល់សិស្ស ប្រមូលសិស្ស ។ សិស្សគប្បីមកដល់សាលាឱ្យទាន់ស្គរឬជួង ឬកណ្ដឹងលើកទីមួយ ។

សិស្សមកមិនទាន់ម៉ោងជាហេតុនាំឱ្យមានទម្លាប់អាក្រក់ ធ្វើអ្វីៗក្នុងជីវិតនេះតែមិនត្រូវ ឬមិនទាន់ពេលវេលា និងជាកិច្ចមិនគួរសមចំពោះគ្រូនឹងចំពោះសិស្ស ។ មិនគួរសមយ៉ាងណាមិញ គឺមិនគួរសិស្សមកដល់ក្រោយគ្រូ ធ្វើឱ្យលោកគ្រូនឹងមិត្តឯងទៀតចាំ ។ បទនេះចាត់ទុកជាបទមើលងាយដល់គ្រូ និងមិត្តជាសិស្សក៏បាន ។ ម៉្យាងទៀត ជាកិច្ចរំខានដល់ថ្នាក់រៀន ដែលបានចាប់ផ្ដើមខ្លះទៅហើយ ។

តែផ្ទុយទៅវិញ សិស្សមិនត្រូវមកមុនម៉ោងជ្រុលពេកទេ ហើយទុកឱកាសមុនចូលរៀននោះទៅលេង ឬប្រព្រឹត្តបទណាដែលឆ្គងពីការរៀនដូចជា គប់ផ្លែឈើ ហែលទឹក ជាដើម ។ ល្បែងនឹងអំពើប្រព្រឹត្តមុនម៉ោងចូលរៀន នឹងក្រៅសាលា អាចនាំក្មេងឱ្យមានគ្រោះថ្នាក់( ធ្លាក់ពីដើមឈើ លង់ទឹក-ដាល់គ្នា ) ។ តាមទម្លាប់ធ្លាប់ដឹងឮមក គ្រូត្រូវទទួលខុសត្រូវលើសិស្សតែនៅ ១៥នាទីមុនចូលរៀន - កំពុងរៀន - ពេលចេញលេង និង៥នាទីក្រោយចេញពីរៀន ហើយសំខាន់គឺពេលសិស្សនៅក្នុងក្របខណ្ឌបេងក្នុងវង្វង់សាលារៀន ។

## មេរៀនទី ២៧ - ចេះស្លៀកពាក់ក្នុងសាលា

រឿងសម្លៀកបំពាក់ យើងបានថែងខ្លះហើយនៅលំនាំដើម រឿងសំអាតខ្លួន ដោយចំពោះជារឿង អនាម័យទេ ។ តែតាមបទសុភាវធម៌ សិស្សត្រូវស្លៀកពាក់កុំបណ្តែតបណ្តោយ ដោយតាំងចិត្តថា ខ្លួនទៅកន្លែង មួយដែលជាទីគោរព មិនមែនទៅលេងឡេះឡោះ ស្លៀកពាក់បានតាមចិត្តនោះទេ ឬក្នុងការស្លៀកពាក់នោះ មានការខ្ជីខ្ជា( មិនដាក់ឡេវអាវ-មូរដៃអាវម្ខាង ) ។ ត្រង់នេះគួររំឭកពីរឿងរបៀបផ្លាស់ខោអាវនៅក្នុងសាលា ត្រូវប្រព្រឹត្តដោយគោរពកេរ្តិ៍ខ្មាសបំផុត បើមានសិស្សប្រុសនឹងស្រីលាយឡំគ្នា ។

តាមរបៀបទំនើបសាលាគួរមានបន្ទប់មួយសម្រាប់សិស្សប្រុស បន្ទប់មួយសម្រាប់សិស្សស្រី ។

ខោខ្លីស្លៀកសម្រាប់កីឡា ត្រូវឱ្យសមទៅតាមខ្នាតកីឡា មិនត្រូវស្លៀកខោទ្រនាប់ធម្មតាដែលមានពណ៌មិនសម ។

ស្លៀកខោខ្លីហើយកុំឆ្លៀតលាត់សៀតចង្កេះទៀត ។ រួមសេចក្តីគឺរបៀបស្លៀកពាក់ ត្រូវស្ថិតនៅគោលគំនិតដូចតទៅនេះ ឱ្យមានភាពសមរម្យ ឱ្យមានរបៀបជាបទចរិយាសាស្ត្រខ្លះ ។

ត្រូវរំឭកដល់សិស្សនៅការទ្រទ្រង់រាងកាយទូទៅ មានការកាត់សក់ ការកាត់ក្រចក និងរៀបខ្លួនឱ្យមានសភាពជាកុមារមានសណ្តាប់ធ្នាប់ គឺកុំឱ្យរាងកាយ ជាហេតុទំនាស់ដល់ភ្នែកអ្នកផង ។

## មេរៀនទី ២៨ - តាក់តែងកាយចំពោះសិស្សនារី

ចំពោះកុមារី គួរបញ្ជាក់នូវរបៀបដោយឡែកខ្លះ ចៀសវាងកុំឱ្យសិស្សស្រីចិញ្ចឹមចិត្តថា ត្រូវតែងខ្លួនដូចជាមនុស្សស្រីពេញរូបពេញរាងទៅហើយ គឺចៀសវាងពាក់អាវទំនើបសម័យដែលចាប់រាងពេមិនខ្មោះ ឬជាសំពត់ស្តើងឃើញសាច់ ។ ការថែទាំសក់ មានការអ៊ុត - ការចាប់រាងក្បាល - ការលាបមុខ - ផាត់ម្សៅ - ប្រើទឹកអប់ - ពាក់មាសពាក់ពេជ្រ ក៏ត្រូវតែបន្ថយដោយរក្សាគោលគំនិតថា កុមារីមិនត្រូវតែងខ្លួនឱ្យហួសឋានៈជាសិស្សស្រីចូលដល់ឋានៈមនុស្សស្រីពេញរូបពេញរាងទេ ។ ការធ្វើកាយវិការសំដីសំដៅ - ទឹកមុខ - ដាក់ឫកពា - របៀបដើរ ក៏ត្រូវគិតប្រព្រឹត្តឡើងទៅតាមគោលការណ៍ថា សិស្សស្រីជាកុមារីឬយុវតី សិក្សាមិនមែនជាស្រីពេញរូបពេញរាងទេ ។

## មេរៀនទី ២៩ - ពិធីគោរពទង់ជាតិ

មុននឹងចូលរៀនមានពិធីគោរពទង់ជាតិ ។ តើពិធីនេះមានន័យយ៉ាងណា ?

ដំបូងជាកិច្ចប្រមូលសិស្សឱ្យឈរជាជួរ ឱ្យច្រៀងបទនគររាជដែលជាសញ្ញាភ្លេងនឹងទំនុកជាតិខ្មែរ ។ ពេលនោះសិស្សម្នាក់បង្ហូតទង់ជ័យជាតិខ្ពស់ត្រដែតទៅ ។ នៅនាទីនោះសិស្សត្រូវមានចិត្តក្តួចឆ្ពោះដល់ជាតិខ្មែរ - សាសនា - ព្រះមហាក្សត្រ ។ នាទីគោរពទង់ជាតិទាញអារម្មណ៍ក្មេងឱ្យវិលមកប៉ះគោលគំនិតមួយថ្ងៃបានពីរដង ។ បទសុភាវធម៌ដែលត្រូវទាញចេញ នៅពេលគោរពទង់ជាតិ ខាងផ្លូវកាយ ត្រូវឈររបៀបប្រុង - របៀបជាគោរព - មានសម្បជញ្ញៈច្រៀងបទនគររាជ - ច្រៀងឱ្យត្រូវបទភ្លេង - ត្រូវសម្លេង ។ ត្រូវមានចិត្តគោរពនឹងស្រលាញ់ ។ ខាងផ្លូវចិត្តនៅនាទីគោរពទង់ជាតិ ធ្វើចិត្តកុំឱ្យរវើរវាយនឹកទៅឯណា តែត្រូវតាំងចិត្តនឹកស្រលាញ់គោរពជាតិ - សាសនា - ព្រះមហាក្សត្រ ។

នៅពេលបញ្ចប់ពិធីគោរពទង់ជាតិ សិស្សមិនត្រូវស្រែកហ៊ោកញ្ជ្រៀវទេ តែត្រូវរៀបជាជួរដោយវិន័យបម្រុងនឹងចូលរៀន ។

# មេរៀនទី ៣០ - ការគោរពគ្រូ

នៅក្នុងសាលា គ្រូជាបុគ្គលដែលសិស្សត្រូវស្រលាញ់ហើយគោរព : គោរពលោកដោយវាចា គឺនិយាយដោយសំដីទន់ភ្លន់មានប្រយោគ-ប្រធាន ។ កុំនិយាយកំបុត ហើយប្រើពាក្យឱ្យគួរសមទៀត ។ តាមធម្មតាសិស្សត្រូវឈរ ឈរឱ្យត្រង់ កុំមាត់ កុំងាកមុខចុះឡើង ភ្នែកសម្លឹងរកប្រឡែងគ្នា ជាកិច្ចគោរពគ្រូនៅពេលចូលរៀនម៉ោងដំបូង ។ នេះជាបទគោរពតាមកាយវិការ បើលោកគ្រូហៅ ត្រូវឈរភ្លាម បើត្រូវការចេញចូល ត្រូវសុំច្បាប់លោកគ្រូ ។

បើលោកគ្រូនិយាយ ត្រូវប្រុងស្តាប់ កុំធ្វើឫកពាព្រងើយ ។ ត្រូវចៀសវាងជាដាច់ខាតចំអកឡកឡើយដល់លោកគ្រូ និយាយដើមពីគ្រូ និងសម្តែងអាការៈណាមួយធ្វើឱ្យលោកគ្រូមិនសប្បាយចិត្ត ។

# មេរៀនទី ៣១ - សិស្សគ្រូ-និងភ្ញៀវសាលា

បើយើងមានវត្ថុអ្វី ដែលត្រូវជូនទៅលោកគ្រូ ត្រូវហុចទៅជូនលោកដោយដៃពីរ ទទួលវត្ថុពីលោកក៏ទទួលដោយដៃពីរ ។ ចំពោះមិត្តស្មើគ្នា ហុចវត្ថុនឹងទទួលវត្ថុ ត្រូវប្រព្រឹត្តឡើងដោយដៃស្តាំ ។

ត្រូវរំឭកមេរៀនមុនៗដែលសិស្សត្រូវនិយាយថា "សូមអរគុណ" ។

កំពុងរៀន បើមានមនុស្សប្លែកចូលមក សិស្សត្រូវក្រោកឈរជាកិច្ចគោរពភ្ញៀវដែលចូលក្នុងថ្នាក់ ។ ពេលដែលភ្ញៀវនោះរវល់ជាមួយនឹងគ្រូយើង យើងមិនត្រូវឆ្លៀតពេលនោះជជែកគ្នាឡើយ ត្រូវរក្សាសេចក្តីស្ងៀមស្ងាត់ អង្គុយឱ្យនឹងនួន ដើម្បីកុំឱ្យរំខានលោកគ្រូយើងនឹងភ្ញៀវ ។ ដល់ភ្ញៀវចេញទៅវិញ សិស្សក៏ត្រូវក្រោកឈរជាកិច្ចគោរពភ្ញៀវ ។ ភ្ញៀវចេញទៅមិនទាន់ផុត កុំសម្តែងនិយាយដើមឬចំអកឡកឡឺយឱ្យភ្ញៀវ ។

# មេរៀនទី ៣២ - អាការៈគោរពគ្រូ

នៅក្នុងថ្នាក់ដូចតែនៅកន្លែងនានា សិស្សត្រូវប្រុងជួយបម្រើអ្នកផងជាកិច្ចបន្តិចបន្តួច ដូចជាបើកទ្វារឱ្យគេចូល យកកៅអីឱ្យគេអង្គុយ ។ ការបន្តិចបន្តួចនេះ ជាភាពសុភាវធម៌យ៉ាងល្អ គួរតែសិស្សមានស្មារតីប្រុងបំពេញឱ្យបានរាល់ពេលវេលា ។ បើយើងជាអ្នកបានទទួលអំពើល្អណាមួយពីគេវិញ ត្រូវកុំភ្លេចអរគុណគេភ្លាមៗ ។ បើគ្រូស្តីបន្ទោសឬហាមប្រាមបទណាមួយ ត្រូវយើងទទួលសេចក្តីបន្ទោសនឹងសេចក្តីហាមប្រាមនោះដោយចិត្តរីករាយ កុំធ្វើទឹកមុខក្រញូវរឹងរូសមិនចង់ស្តាប់ ។

បើមានឱកាសខ្លះ យើងបានជាជ្រុលខ្វះការគួរសមដល់លោកគ្រូនូវបែបបទណាមួយ ត្រូវឆាប់កែខ្លួនដោយទៅសុំទោសលោកគ្រូនោះភ្លាម ។

ការសម្តែងការគោរពតាមរបៀបខ្មែរចំពោះអ្នកធំ ត្រូវសំពះដៃពីរ ។ បញ្ហាសំពះនេះ ត្រូវមានរបៀបកម្រិតឱ្យត្រូវក្បួនខ្នាត ។ តែឥឡូវនេះយើងបញ្ជាក់ថា នឹងសំពះត្រូវឈរឱ្យត្រង់ ឱ្យសមរម្យ លើកដៃភ្ជាប់គ្នាឱ្យទំនង កុំប្រងេងប្រងាង កុំធ្វើឡើងដោយប្រញិបប្រញាប់ពេកឱ្យតែរួចពីដៃ ។

ជំពូកសុភាវធម៌នៅក្នុងសាលានេះ គ្រូអាចមានឱកាសច្រើនណាស់ដើម្បីនឹងអប់រំសិស្ស ដោយយលគោលការណ៍តទៅនេះជាមូលដ្ឋាន ៖

ឱ្យសិស្សមានសភាពក្រៅ - កាយវិការ - វាចាសំដីសំដៅ - សន្តានចិត្តសមរម្យ គឺមានសម្បជញ្ញៈដរាប។

# មេរៀនទី ៣៣ - ចំពោះមិត្តភក្តិ រវាងមិត្តភក្តិ

មិត្តភក្តិនៅសាលាជាកុមារ-កុមារីទាំងឡាយ ដែលនៅរៀនក្នុងសាលាជាមួយគ្នា ដោយចំពោះក្នុងថ្នាក់ជាមួយគ្នា ។ ចំពោះមិត្តភក្តិនេះ កុមារ សិក្សាមានការទាក់ទងស្ទើរតែរាល់ថ្ងៃ ។ ដូច្នេះតោងមានបទសុភាវធម៌ដើម្បីការទាក់ទងនេះ បានធ្វើឡើងដោយរីករាយនិងដោយប្រពៃ ។

ដំបូងកុមារាត្រូវចេះយកអាសាមិត្តភក្តិ ពោលគឺឱ្យតែមានឱកាសត្រូវជួយមិត្តភក្តិ - បម្រើមិត្តភក្តិ - ធ្វើកិច្ចល្អណាមួយឱ្យមិត្តភក្តិបានសុខស្រួលបានសប្បាយដោយសារ ។ ការយកអាសាមិត្តភក្តិនេះ មិនត្រូវធ្វើឡើងដើម្បីបញ្ចេញឫកពាបង្ហាញអ្នកផងថាជាក្មេងចិត្តល្អនោះទេ តែធ្វើឡើងដោយសុទ្ធចិត្ត ដោយចិត្តរីករាយ ។

ការមិនជួយយកអាសាគ្នាជាហេតុនាំឱ្យនៅជាមួយគ្នាដោយមិនស្រុះស្រួល ដោយប្រកាន់តែប្រយោជន៍ផ្ទាល់ខ្លួនម្នាក់ៗ រហូតដល់មានចិត្តឈ្នានីសគ្នា ។ អំពើទាំងនេះ ត្រូវកុមារចៀសវាងដោយដាច់ខាត ។

## មេរៀនទី ៣៨ - កុំរំខានអ្នកផង

ការរស់ជាមួយគ្នា បើយើងមិនប្រុងស្មារតី មិនបានជាគិត ខ្លួនយើងនេះឯងអាចទៅជាគ្រឿងរំខានអ្នកផងឯទៀត ។

រំខានដល់កាយគេ ដោយយើងធ្វើកាយវិការមិនសមទៅលើគេ-ដោយទៅឈរបាំងមុខគេ ក្រអឺតដាក់គេ ដោយអង្គុយប្រជ្រៀតនឹងគេ ដោយធ្វើអាការៈក្រៅបែបណាមួយជាធំទាស់ដល់គេ ។

រំខានគេខាងផ្លូវចិត្តដោយប្រើវាចាយ៉ាងខ្លាំងទៅរំខានសេចក្តីស្ងប់ស្ងៀមរបស់គេ ដោយនិយាយពាក្យចំអាសចំអូងឱ្យគេឮ ដោយសម្តែងអាការៈចង់ដឹងអាថ៌កំបាំងរបស់គេ ដោយប្រើសំដីបោះបោកទ្រគោះដល់គេ គឺធ្វើអាការៈទាំងឡាយណាដែលនាំឱ្យគេមានទឹកចិត្តមិនស្រួល ។

កុមារត្រូវចាំខ្ជាប់ក្នុងចិត្តថា ក្នុងលោកនេះខ្លួនត្រូវតែរស់ជាសង្គមជាមួយគេជាដរាប ។ ដូច្នេះតាំងតែពីការដាក់ទឹកមុខឡើង មិនត្រូវធ្វើទឹកមុខក្រញូវ ទឹកមុខស្រងូតស្រងាត់ជ្រុល ទឹកមុខព្រួយហួសហេតុ ដែលអាចជាហេតុនាំឱ្យអ្នកផងឯទៀតពិបាកចិត្តដោយសារខ្លួន ។ ក្នុងអន្លើនេះគោលគំនិតជាមូលដ្ឋានដែលត្រូវចាំ គឺកុមារត្រូវប្រុងស្មារតីជានិច្ចកុំឱ្យសភាពក្រៅរបស់ខ្លួន( ទឹកមុខ - កាយវិការ - សម្លៀកបំពាក់ - សំដីសំដៅ) ទៅរំខានអ្នកផង តែរក្សាអាកប្បកិរិយា - ទឹកមុខស្រស់បស់ - សំដីសំដៅទន់ភ្លន់ ជាហេតុនាំអ្នកផងឱ្យរីករាយជាមួយយើង ។

# មេរៀនទី ៣៩ - ចេះឈ្នះ ចេះចាញ់

ការរស់នៅជាសង្គមក្នុងសាលា រមែងមានការប្រកួតប្រណាំង ការប្រជែងជានិច្ច ដូចនៅក្នុងល្បែងកីឡា នឹងនៅក្នុងការរៀនសូត្រ ។ កុមារត្រូវយល់ថា ការប្រកួតប្រណាំងនេះ ជាកិច្ចនាំឱ្យសិស្សម្នាក់ៗ ខិតខំដោយមធ្យោបាយយុត្តិធម៌ ដើម្បីបានជោគជ័យលើមិត្តរបស់ខ្លួន ។ របៀបប្រកួតប្រណាំងជាហេតុមួយអាចដឹកនាំកុមារឱ្យប្រព្រឹត្តអ្វីៗកាន់តែបានល្អឡើង ។ អ្នកអប់រំគេតែងយករបៀបប្រកួតប្រណាំងនេះ ទៅធ្វើជាមធ្យោបាយ ដើម្បីកំចាត់ពីគំនិតក្មេង នូវទោសពីរយ៉ាង ៖

- ម្យ៉ាងទោសដែលមានះនឹកថា ខ្លួនជាមនុស្សអន់ជាងគេ ម្ល៉ោះហើយគំនិតអន់នេះមកគ្រប់ដណ្ដប់ក្មេងឱ្យខ្លាចមិនហ៊ាននិយាយស្ដី ឬធ្វើអ្វីឡើងចេះតែតាំងខ្លួនជាមនុស្សចាញ់ជានិច្ច ។ កូនខ្មែរយើង-ដោយប្រទេសយើងធ្លាប់នៅខ្ញុំចំណុះគេ រមែងមានចិត្តចាញ់នេះច្រើនណាស់ ។ ផ្ទុយទៅវិញទោសម្យ៉ាងទៀតគឺកុមារដែលដាក់ចិត្តខ្ពស់ពេកថាខ្លួនចេះតែគ្រាន់បើជាងគេទាំងអស់ ក៏កើតចិត្តព្រហើនមើលងាយមិត្តឯទៀត ឬជោរល្មើយខុសទំនង ។

គ្រូត្រូវដឹកនាំក្មេងឱ្យស្គាល់តម្លៃពិតរបស់វា ដោយបង្កើតឱ្យមានការប្រកួតប្រណាំងដោយយុត្តិធម៌ ។ ក្នុងការប្រកួតប្រណាំងនេះ លទ្ធផល ធម្មតាត្រូវតែមានចាញ់ឈ្នះជាដរាប ។ បើយើងត្រូវចាញ់នោះ កុមារត្រូវទទួលចាញ់ដោយសុទ្ធចិត្ត គឺព្រមក្នុងចិត្តថា គេបានឈ្នះយើងដោយយុត្តិធម៌ ដោយគេប្រឹង ដោយគេឆ្លាតជាងយើង ។ ពេលចាញ់កុមារមិនត្រូវសម្ដែងអាការៈឈ្នានីសជោគជ័យរបស់មិត្តភក្តិទេ ឬបង្កើតហេតុអាក្រក់ណាមួយទៅបំផ្លាញជោគជ័យមិត្តភក្តិតាមមធ្យោបាយអយុត្តិធម៌ទេ ។

ផ្ទុយទៅវិញត្រូវមានការសរសើរដោយសុទ្ធចិត្ត ។ សិស្សដែលមានជោគជ័យនេះសោតទៀត ត្រូវបញ្ចេញសំដី ឬកាយវិការណាមួយឱ្យឃើញថា ខ្លួនសមជាប៉ុនពូកែមែន ប៉ិនប្រសប់មែនក្នុងក្ដីយុត្តិធម៌ដោយមិនហួសហេតុពេក ។

# មេរៀនទី ៣៦ - ចៀសវាងការជម្លោះ

វាងមិត្តភក្តិក្នុងសាលារៀន ត្រូវចៀសវាងការជម្លោះដោយបង្កើតឱ្យមានការជជែកគ្នាតឹងសំដីរហូតមានការប្រវាយប្រតប់គ្នា ។ ការជម្លោះនេះអាចកើតឡើងដោយការច្រណែននិន្ទា ដោយចិត្តអាក្រក់ ចង់ឱ្យតែមិត្តភក្តិចាញ់ខ្លួន ថោកទាបជាងខ្លួន ឬមកពីការជជែកដោយប្រកាន់យកត្រូវតែម្នាក់ឯង មិនព្រមរំលែកយោបល់មិត្តភក្តិផង ។

កុមារត្រូវចៀសវាងការជម្លោះប៉ុន្មានប្រភេទនេះដោយដាច់ខាត គឺកុំឱ្យមានជជែកតឹងសំដី វាងការប្រវាយប្រតប់គ្នាវាងគ្នា ឱ្យរស់ជាមួយគ្នាដោយញញឹមសុខស្រួល ដោយមានសុភាវធម៌រកគ្នាទៅវិញទៅមក និងដោយរក្សាចិត្តស្រលាញ់គ្នាជានិច្ច ។

# មេរៀនទី ៣៧ - បើមានមិត្តពិការ

បើមានមិត្តភក្តិណាមួយមានពិការ( បាក់ដៃ-បាក់ជើង-ត្រជិត-ខ្វាក់ម្ខាង )ជាដើម កុមារត្រូវកុំចំអកឡកឡឺយដោយទឹកមុខ ដោយការធ្វើតម្រាប់តាម ដោយសំដីបញ្ចិតបញ្ចៀងដល់មិត្តពិការនោះឱ្យសោះ ។ តែយើងត្រូវធ្វើដូចជាមិនដឹងខ្លួន មិនចាប់អារម្មណ៍ថាមិត្តយើងជាមនុស្សខុសពីយើងដោយមានពិការភាព ។ ត្រូវរក្សាទឹកមុខធម្មតាឱ្យមិត្តពិការនោះជឿក្នុងចិត្តថា គ្នាមិនខុសពីយើងទេ ។ តែតាមធម្មតា មិត្តពិការរមែងត្រូវការរាប់អានពីមិត្តឯទៀតណាស់ ដូច្នេះ កុមារត្រូវដឹងទុក្ខធុរៈមិត្តពិការ ត្រូវជួយដោះទុក្ខគ្នា ក្នុងរឿងជីវិតធម្មតាដែលកើតឡើងដោយពិការភាពនោះ ។ ឧទាហរណ៍ បើមិត្តយើងបាក់ជើងម្ខាង បើមានការត្រូវឡើងជណ្តើរខ្ពស់ ត្រូវយើងជួយដឹកដៃ ។

# មេរៀនទី ៣៨ - មិត្តសិស្សស្រីប្រុស

សិស្សប្រុសនិងសិស្សស្រី ដោយហេតុមានភេទខុសគ្នាក្នុងការទាក់ទងរវាងគ្នា ត្រូវធ្វើឡើងឱ្យសមរម្យ ។ សិស្សប្រុសមិនត្រូវនិយាយចំពោះមុខសិស្សស្រីនូវរឿងខ្លះដែលយើងអាចនិយាយប្រាប់បានតែសិស្សប្រុស ។ ការធ្វើកាយវិការរបៀបនិយាយលេងក៏ដូច្នោះដែរ គឺនៅចំពោះមុខមិត្តស្រី យើងត្រូវធ្វើផ្សេងពីចំពោះមុខមិត្តប្រុស ដោយចៀសវាងធ្វើអំពើទៅប៉ះទង្គិចសេចក្ដីអៀនខ្មាសរបស់ស្រី ក៏មានសុភាវធម៌ដូចសិស្សប្រុសដែរ ។ នៅចំពោះមុខមិត្តប្រុស ត្រូវមានសំដីសំដៅ-កាយវិការផ្សេងពីនៅចំពោះតែស្រីគ្នាឯង ។

ត្រង់នេះត្រូវរំឭកជូនកាលមានការផ្លាស់ខោអាវ លេងល្បែងកីឡា ឬលេងរបាំសិល្បៈជាដើម ស្រីត្រូវធ្វើដោយប៉ែកស្រី ប្រុសត្រូវធ្វើដោយប៉ែកប្រុស កុំឱ្យច្របូកច្របល់ មានការស្និទ្ធស្នាលជ្រុល ។

ទំនៀមទម្លាប់បារាំងនឹងខ្មែរខុសគ្នាខ្លាំងណាស់ក្នុងរឿងនេះ ។ ខ្មែរយើងដូចយើងដឹងស្រាប់ ច្រើនប្រកាន់មិនឱ្យស្រីប៉ះពាល់ សូម្បីតែដៃជើងគ្នាក៏មិនបានផង ។ ឯបារាំងវិញ ទំនៀមទម្លាប់គេមិនសូវប្រកាន់ទេ ។ កុមារស្រីប្រុសកាន់ដៃ កាន់ជើងគ្នាជាការធម្មតារហូតដល់ឱបថើបគ្នាជាការគួរសមរវាងមិត្តនិងមិត្តផង ។

យើងជាកូនខ្មែរថ្វីត្បិតបានរៀនបារាំងខ្លះ មិនត្រូវយលទម្លាប់បារាំងនេះមកប្រតិបត្តិឱ្យជំទាស់នឹងទំនៀមទម្លាប់ខ្មែរទេ ។ តែយើងក៏មិននៅប្រកាន់របៀបចាស់ហួសសម័យទៅហើយដែរ ។

សុភាវធម៌របស់សិស្សនៅក្នុងសាលាចំពោះគ្រូ នឹងចំពោះភ្ញៀវមកសាលា នឹងចំពោះមិត្តភក្តិ មានច្រើនណាស់ ។ បើគ្រូប្រុងចាំតែសង្កេត អាចឃើញអំពើសិស្សមិនសមរម្យស្ទើរតែរាល់នាទីក្នុងសម័យបច្ចុប្បន្ននេះ ។

បើគ្រូសង្កេតបានឃើញមិនសមរម្យត្រង់ណាហើយ អាចទាញយកមកធ្វើជាមេរៀនបង្ហាត់បង្ហាញសិស្សដោយសេរីបាន ។

# ជំពូកទី ៦

# អាកប្បកិរិយាដែលត្រូវប្រព្រឹត្តនៅទីកន្លែងសាធារណៈ




## មេរៀនទី ៣៩ - កុមារនៅទីកន្លែងសាធារណៈ

សិស្សសាលាមិនមែនត្រូវតែមានសុភាវធម៌ក្នុងគ្រួសារ និងក្នុងសាលាប៉ុណ្ណោះទេ ។ កុមារសិក្សាដែលល្អកុំឱ្យកុមារយល់ថា : "អញចង់ធ្វើអ្វីបានតាមចិត្ត " ។ ផ្ទុយទៅវិញគឺនៅទីសាធារណៈនេះហើយ ដែលកុមារមានការទាក់ទងចំពោះមនុស្សច្រើនប្រភេទឥតគណនា ។ ដូច្នេះកុមាររឹតតែប្រុងស្មារតីរក្សាសុភាវធម៌ឱ្យបានខ្ជាប់

ខ្លួន ហើយឱ្យប្លែកៗទៅតាមកាលៈទេសៈ ទៅតាមទីកន្លែង នឹងទៅតាមប្រភេទមនុស្សដែលយើងទាក់ទង ។ នៅលំនាំដើមនេះ គួររំឭកថា ក្នុងឋានៈជាសិស្សសាលា កុមារមានករណីកិច្ចមួយត្រូវរក្សាកិត្តិនាម៉ កិត្តិនាមសិស្សសាលា៉ ។ គប្បីមានអ្នកផងថាយុវជនអ្នកសិក្សា ជាយុវជនមានវិន័យ ចេះច្បាប់ទម្លាប់ មានពូជ មិនមែនជាក្រុមយុវជនរដាច់រដោច រលឹមរលោម គ្មានវិន័យឬមានចិត្តមើលងាយអ្នកផងនោះទេ ។

សិស្សខ្លះដោយនឹកក្នុងចិត្តថា អញជាកូនសិស្ស ជាអ្នករៀន ជាក្មេងមិនទាន់ទទួលខុសត្រូវ អញត្រូវមានសេរីភាពជាងគេ អញអាចធ្វើអ្វីបានទាំងអស់ ដូចជាដើរអាឡេអាឡូតាមវិថីឬក្នុងសួនច្បារជាដើម ។ ការយល់ខុសបែបនេះផ្ទុយពីការសិក្សានៅសាលាដោយចំពោះផ្ទុយពីបទសុភាវធម៌យ៉ាងខ្លាំង ។ កិត្តិនាមសាលាទាំងមូយ កិត្តិនាមប្រទេសទាំងមូល គឺផ្ញើនៅលើឫកពាសិស្សនៅទីសាធារណៈនេះហើយ ។



# មេរៀនទី ៤០ - កុមារនិងច្បាប់ចរាចរ

ការចរាចរនៅទីក្រុងធំៗ ជាបញ្ហាស្មុគស្មាញមួយ ដែលពិបាកនឹងដោះស្រាយ ។ វិទ្យាសាស្ត្របង្កើតរថយន្តកាន់តែលឿនឡើង ។ ការគ្រោះថ្នាក់ក៏កាន់តែមានច្រើនឡើង ។ អ្នកបរឡានដែលបុកគេដោយខុសច្បាប់ គេទុកជាពេជ្ឈឃាតមួយ ។ ដើម្បីនិងរៀបចរាចរនេះឱ្យរៀបរយ គឺចៀសវាងការគ្រោះថ្នាក់ រាជការចងក្រងជា

បទបញ្ជា ដោយមានធ្វើសញ្ញាជារបេភាពឬជាភ្លើងឬជាសម្លេងកណ្ដឹង ។ រាជការថែមទាំងមានចាត់ភ្នាក់ងារឱ្យឈរបាំទីកន្លែងប្រជាជនធ្វើសញ្ញាឱ្យអ្នកចរាចរប្រតិបត្តិតាម ថែមទាំងមានភ្នាក់ងារដើរត្រួតគ្រប់កន្លែង ។ គ្រោះថ្នាក់ ក៏គង់នៅមាន ។

កុមារត្រូវមានសុភាវធម៌ដោយជាក់លាក់ណាស់ចំពោះច្បាប់ចរាចរនេះ ។ ដំបូងត្រូវដឹងគោលនឹងបទបញ្ជាចរាចរខ្លះ គឺសញ្ញាជារូបភាព ជាភ្លើងពណ៌ ឬជាសម្លេងដែលបញ្ជាឱ្យយើងឈប់ ឱ្យយើងដើរ ។ ដល់ចេះហើយត្រូវប្រតិបត្តិឱ្យបានជាក់លាក់ ។

កុមារខ្លះ យកការធ្វើដំណើរតាមវិថីជាការសប្បាយ ការចង់ប្រជែងឱ្យបានលឿនជាងគ្នា នេះជាបទខុសមួយយ៉ាងខ្លាំង ។ ការធ្វើដំណើរក្នុងវិថីត្រូវប្រុងប្រយ័ត្នកុំមានចិត្តរំលោភ ព្រហើនមើលងាយអ្នកផងឯទៀតដោយចង់កៀងដំណើរគ្នាយកឈ្នះ យកចាញ់ ។

ក្រុងដែលមានរបៀបរៀបរយហើយ មានលក្ខណៈចរាចរខ្លះដែលសិស្សគួរដឹងដូចតទៅ ៖

គេមានបោះជាដែកគោលធំៗ កាត់ផ្លូវជាចន្លោះទុកឱ្យសាធារណៈស្វ័យប្រវត្តិ ភ្លើងក្រហមរថយន្តត្រូវឈប់ អ្នកដើរឆ្លងផ្លូវតាមចន្លោះដែលគោលដែលបានចែងមកហើយ ។ ភ្លើងលឿងត្រូវប្រុងទាំងអ្នកដើរ ទាំងរថយន្ត ព្រោះមានការផ្លាសប្តូរឥឡូវហើយ ។ ភ្លើងបៃតង រថយន្តត្រូវទៅ អ្នកដើរត្រូវឈប់ចាំ ។ មានបង្កើតឱ្យមានវថីក្រុងជំនួសយានតូចៗ ដូចជាស៊ីក្លូជាដើម ។ មានវិធានការណ៍កុំឱ្យស្នូរសម្លេងឮពេក បង្គាប់ទៅរថយន្តកុំឱ្យបន្លឺសម្លេងញាប់ពេក នឹងមិនឱ្យមានពពាយនាយលក់ឥវ៉ាន់ ។ បើយប់ត្រូវហាមសោះតែម្តង ។

សម្លេងទីក្រុងអាចជាហេតុនាំឱ្យវក់ស្មារតីពលរដ្ឋនៅទីក្រុងផង ។

គោលៗទាំងនេះគប្បីកុមារដឹង ព្រោះរាជធានីភ្នំពេញ កាន់តែខិតចូលទៅកាន់ភាពទីក្រុងធំបែបអន្តរជាតិហើយ ។

នៅទីសាធារណៈយើងក៏ត្រូវចៀសវាង និយាយពាក្យចំអាសចំអូង ។

ដូច្នេះនៅទីសាធារណៈ យើងគោរពការស្ងៀមស្ងាត់របស់អ្នកផង ដោយនិយាយគ្នាហឹមៗ ឱ្យស្តាប់បានតែគ្នាឯង ហើយកាន់អាកប្បកិរិយាថ្លៃថ្នូរជានិច្ច ។

នៅអឺរ៉ុប គេគ្មានស្រែកប្រកូកហៅគ្នានៅតាមថ្នល់ឬស្រែកឡូឡាជាក់គ្នា នៅពេលជួបគ្នាឡើយ ម្នាក់ៗរក្សាភាពសមរម្យរបស់គេរៀងៗខ្លួន ។ ទម្លាប់ល្អនេះគួរខ្មែរយើងប្រតិបត្តិតាម ។

# មេរៀនទី ៤១ - គោរពសួនច្បារ

ការគោរពទីស្ថានសាធារណៈមួយបែបទៀត ត្រូវប្រព្រឹត្តឡើយដោយ ចៀសវាងចោលរបស់ក្រខ្វក់ មាន សំបកផ្លែឈើជាដើម ទៅលើទីស្មៅដែលដាំ ។ សួនច្បារជាកន្លែងលំអមួយដែលបង្កើតបរិយាកាសរីករាយដល់អ្នកផង ។ ចុះបើយើងយកវត្ថុក្រខ្វក់មួយទៅបោះចោលនៅទីនោះ ភាពល្អក៏ល្អក់បាត់អស់ ។ យើងជាអ្នកបានបំផ្លាញភាពល្អ ។ បើកាលៈទេសៈនាំយើងឱ្យបរិភោគអ្វីលើវាលស្មៅ ក្រោយពីពេលបរិភោគហើយ ត្រូវប្រមូលរៀបចំសំបកឈើនិងសំណល់អាហារបោសចោលឱ្យស្អាត កុំទុកឱ្យមានជាសំណល់បំផ្លាញភាពល្អនៃធម្មជាតិនោះ ។

កុំទម្លាប់បេះបោចផ្កានិងផ្លែឈើដែលនៅក្នុងសួនសាធារណៈ ។ ផ្កានឹងផ្លែទាំងនេះ ជារបស់រាជការ គឺជារបស់ទាំងអស់គ្នា ។ មិនមែនតែមិនគោរពដល់សួន ដល់ធម្មជាតិប៉ុណ្ណោះទេ ថែមទាំងអាចចាត់ទុកជាអ្នកលួចរបស់សាធារណៈផង ។

ទម្លាប់អាក្រក់របស់ខ្មែរយើងមួយបែបទៀត ច្រើននាំគ្នាបត់ជើងតូចធំនៅទីសួន ។ ទម្លាប់នេះជាទម្លាប់ខុសបំផុត ត្រូវចៀសវាង ។ សួនច្បារជាកន្លែងសិរីសួស្តី ជាកន្លែងរីករាយដែលអ្នកផងមកកំសាន្ត មកយកខ្យល់អាកាសល្អ ។ ចុះបើយើងនាំគ្នាបត់ជើងបត់ដៃទីនោះ សួននឹងមានសភាពយ៉ាងដូចម្ដេចទៅវិញ ។

នៅទីក្រុងធំៗ មានក្រុងប៉ារីសជាដើម គេមានធ្វើសួនល្អៗ ណាស់ដើម្បីឱ្យពលរដ្ឋមកសម្រាកដើរលេងនៅទីនេះ ។ រាជធានី និងទីក្រុងយើងនៅខេត្តខ្លះកាន់តែមានសភាពនេះជាលំដាប់ហើយ ។

# មេរៀនទី ៤២ - អំពីស្តោះ និងកណ្តាស់

ការស្តោះ និងកណ្តាសដែលប្រព្រឹត្តឡើងដោយឮ ជាបទរំខានអ្នកផង ។ អ្នកផងអាចល្មើមពីការខាកស្តោះ នឹងការកណ្តាស់នោះ ។ អ្នកខ្លះមិនបានដឹងនូវរឿងនេះ ធ្វើការខាកស្តោះ និងកណ្តាស់នៅមុខគេជាធម្មតា មាននៅពេលបរិភោគ ឬនៅពេលដើរតាមផ្លូវជាដើម ។

ប្រទេសអឺរ៉ុបគេហាមប្រាមមិនឱ្យ ខាកស្តោះរហូតដល់កុំកណ្តាស់ ។ តែបើយើងចៀសមិនរួចត្រូវប្រព្រឹត្តឡើងដោយលាក់លៀម ។

យើងអាចយករបៀបអឺរ៉ុបមកប្រើ គឺម្នាក់ៗ គោងមានកូនកន្សែងដៃមួយ ។ បើត្រូវការស្តោះ យកកន្សែងខ្ទប់មាត់លបស្តោះដាក់កន្សែង ។ បើត្រូវការកណ្តាស់យកកន្សែងខ្ទប់ច្រមុះកណ្តាស់ដាក់កន្សែង បត់កន្សែងនោះដាក់ហោប៉ៅទៅផ្ទះបោកភ្លាម ។

ខ្មែរយើងគប្បីនាំគ្នាប្រឆាំងនឹងការស្តោះ ដែលម្នាក់ៗច្រើនប្រព្រឹត្តឡើងដោយឥតដឹងខ្លួន នៅពេលបរិភោគគុយទាវព្រឹកៗ ពេលបាយ ពេលជិះកង់ឬស៊ីក្លូ( ជួនការស្តោះប៉ើងទឹកមាត់ឬកំហាកមកលើអ្នកជិះក្រោយ ) ។ កំហុសខាកស្តោះ អាចចាត់ទុកជាកំហុសទូទៅនៅប្រទេសខ្មែរ គួរតែមូលមាត់គ្នា នាំគ្នាកុំខាកស្តោះខុសសុភាវធម៌ទៅទៀត ។

## មេរៀនទី ៤៣ - របៀបរៀបរយ

ទីសាធារណៈនីមួយៗ រមែងមានសណ្តាប់ធ្នាប់និងភាពស្ងៀមស្ងាត់របស់គេ ។ យើងមិនត្រូវប្រើអាកប្បកិរិយាណាមួយ ទៅបំបាត់សណ្តាប់ធ្នាប់ និងភាពស្ងៀមស្ងាត់នៃទីសាធារណៈឡើយ ។ ផ្ទុយទៅវិញយើងត្រូវរក្សា និងគោរពសណ្តាប់ធ្នាប់ ។ រាជធានីយើងនិងទីក្រុងខ្លះកាន់តែរីកចម្រើនគួរសមដែរហើយ ។ មនុស្សក៏កាន់តែកើតច្រើន ។ ម្ល៉ោះហើយក្នុងចរាចរក្តី ក្នុងការទិញឥវ៉ាន់ក្តី រមែងមានការប្រជ្រៀតគ្មានសណ្តាប់ធ្នាប់ ។

ច្បាប់សុភាវធម៌ហាមយើងមិនឱ្យប្រជ្រៀតដូច្នេះ ឱ្យយើងចេះ "ធ្វើកន្ទុយ" គឺឈរតគ្នាចាំដល់វេនយើងសឹមចូល ។ អ្នកណាមកមុន គេឈរមុខ អ្នកណាមកក្រោយឥតមានរើសឋានៈឡើយ ។ ការធ្វើកន្ទុយនេះ ច្រើនត្រូវធ្វើនៅចំពោះផ្ទះជំនួញ នៅចំពោះបន្ទប់ទិញសំបុត្រមើលទស្សនីយភាព នៅចំពោះកន្លែងចំណតរថក្រុង និងបង្គន់បត់ជើង ។

ដែលហៅថារថក្រុង គឺរថយន្តធំៗដែលបើកតាមវិថីនៅក្រុង សម្រាប់ដឹកនាំអ្នកទៅមកជំនួសស៊ីក្លូសព្វថ្ងៃនេះ ។ ទីក្រុងធំៗ តែងមានរថក្រុងជាធម្មតា ។ រថក្រុងនេះមានមនុស្សគ្រប់ប្រភាទជិះប្រជ្រៀតគ្នាជាច្រើន ដូច្នេះត្រូវមានច្បាប់សុភាវធម៌នៅលើរថក្រុងជាច្រើនដូចជា ៖

បើប៉ះគេឬជាន់ជើងគេ ឱ្យសុំទោស ប្រុសឃើញមនុស្សស្រី មនុស្សចាស់ឬមនុស្សមានផ្ទៃពោះ មនុស្សពិការ ត្រូវជូនកន្លែងអង្គុយទៅមនុស្សនោះ ។ ត្រូវស្លៀកពាក់ដោយសមរម្យផង កុំកាន់ជាប់នឹងខ្លួនវត្ថុច្រើនពេក វត្ថុណាដែលមានក្លិនស្អុយឆ្អាប ។

# មេរៀនទី ៤៨ - គ្រោះថ្នាក់និងទុក្ខអ្នកដទៃ

កុមារប្រកបដោយសុភាវធម៌ចេះសំដែងអាកប្បកិរិយាចំពោះទុក្ខអ្នកផង ។ នៅទីសាធារណៈ ទុក្ខអ្នកផងរមែងមានដោយ : ការគ្រោះថ្នាក់តាមវិថី ដោយមានក្បួនដង្ហែសព ឬដោយឃើញពិការភាពនៃអ្នកផង ។ នៅចំពោះមុខ ព្រឹត្តិការណ៍ទាំងនេះ កុមារត្រូវមានករុណាធម៌សំដែងឡើង តាមអាកាប្បកិរិយាក្រៅជាភាពសមរម្យ ទឹកមុខស្រងូតស្រងាត់ ឬទៅជួយរំលែកទុក្ខគេតែម្តង ។

បើជាការគ្រោះថ្នាក់ កុមារត្រូវខ្នះខ្នែងសួររកភ្នាក់ងារនគរបាលទទួលខុសត្រូវ ។ បើមានការរបួស យើងជួយសម្រាលជម្ងឺបានប៉ុន្មាន យើងជួយប៉ុណ្ណោះ ហើយអាចជួយជាអ្នកសាក្សីឱ្យព័ត៌មានដោយយុត្តិធម៌ទៀត ។

បើជាក្បួនដង្ហែសព បើមានមួកត្រូវដោះមួក កុំដើរ ឬជិះកង់កាត់ក្បួនដង្ហែសព កុំធ្វើទឹកមុខសប្បាយ កុំបញ្ចេញវាចាខ្លាំង ។ ចំពោះមនុស្សពិការ យើងត្រូវធ្វើកុំឱ្យមនុស្សពិការចាប់អារម្មណ៍ថា យើងកួចចិត្តសង្កេតពិការភាពរបស់គ្នា តែបើគ្នាមានការពិបាកយ៉ាងណាមួយ ត្រូវយើងទៅជួយយកអាសាគ្នាភ្លាម ដូចជាដឹកដៃឆ្លងថ្នល់ជាដើម ។

# មេរៀនទី ៤៩ - របស់ដែលរើសបាន

សុភាវធម៌នៅទីសាធារណៈ មានច្រើនជាអនេក ។ បើសិនជាយើងរើសបានវត្ថុអ្វីមួយ យើងត្រូវជំនះចិត្តលោភរបស់យើង ហើយយកវត្ថុនោះទៅឱ្យភ្នាក់ងារទទួលខុសត្រូវ ពីវត្ថុបាត់ ឬបើឃើញម្ចាស់ ត្រូវឱ្យម្ចាស់គេវិញដោយចិត្តស្មោះត្រង់ឥតក្តួញកាញ់ចង់បានរង្វាន់ពីគេឡើយ ។

# មេរៀនទី ៤៦ - គួរសមនឹងជនដែលគួរគោរព

កុមារប្រុស បើជួបនឹងជនដែលគួរគោរពត្រូវបើកមួកគោរពជននោះដោយទឹកមុខញញឹមញញែម ដោយបន្លឺវាចាសួរបានផងថា ៖

"លោកអ៊ុំអញ្ជើញទៅណាមកណា?" ។ ត្រូវចៀសវាងធ្វើជាមិនឃើញ ហើយធ្វើទឹកមុខក្រអឺតដាក់ ។

# មេរៀនទី ៤៧ - អំពីរថក្រុង

យើងមកដល់អន្លើត្រូវអធិប្បាយពីរថក្រុងទៀត។ មានរថក្រុងជារថយន្តធំៗ ជារថយន្តតែងប្រើកម្លាំងអគ្គីសនីឫជារថអែ រទេះភ្លើងក្រុង ។ នៅក្រុងធំៗ ប៉ារីស ឡុនដុន មូស្គូ ។ល។ មានរថភ្លើងក្រុងបរក្នុងដី តាមផ្លូវដែលជីកក្រោមក្រុង ។ នៅក្រុងធំៗ ដូច្នេះ នៅមានតែឡានតាក់ស៊ី ឯស៊ីក្លូឬរ៉ឺម៉កគ្មានទេ ។ រថក្រុងទាំងនោះ បរមានរយៈ ។ ដល់រយៈ តោងឈប់មានមនុស្សចុះ មានមនុស្សឡើង ។ បទសុភាវធម៌បង្គាប់ថា តាមរយៈត្រូវយើងធ្វើកន្ទុយ"គោរពវេនយើង" មិនប្រជ្រៀត មិនដណ្តើមឡើងឱ្យតែពីខាងបាន ។

នៅក្នុងរថក្រុង តែងមានកន្លែងអង្គុយនឹងកន្លែងឈរ ។ បើយើងមានកន្លែងអង្គុយ ហើយមានមនុស្សស្រីឡើងមកគ្មានកន្លែង សុភាវធម៌បង្គាប់ឱ្យកន្លែងនោះទៅមនុស្សស្រី យើងទៅឈរវិញ ។ ចំពោះមនុស្សពិការស្ត្រីមានគភ៌ក៏ដូច្នេះដែរ ។ បើយើងមានកន្លែងអង្គុយ តោងជូនកន្លែងនៅទៅមនុស្សទាំងនោះ ។

ក្នុងរថក្រុងនេះច្រើនតែចង្អៀត ដូច្នេះយើងត្រូវកុំនិយាយខ្លាំង ។ បើមានការនិយាយគ្នា និយាយខ្សិបៗ កុំជក់បារីបង្ហុយផ្សែង កុំស្តោះ កុំធ្វើកាយវិការប្រងេងប្រងាង ។

ក្រុងភ្នំពេញនឹងមានរថក្រុងក្នុងពេលឆាប់ៗនេះ គប្បីកុមារសិក្សាសុភាវធម៌ក្នុងរថក្រុងឱ្យដឹងជាមុនខ្លះ។

ចំពោះកុមារី បើសិនមានប្រុសឯណា ឱ្យកន្លែងអង្គុយក្នុងរថក្រុងមកយើង យើងត្រូវចេះថា "អរគុណ" ដល់គេ ។ យើងជាក្មេងទោះយើងជាស្រីក៏ដោយ បើឃើញមនុស្សពិការ មនុស្សចាស់ មានមនុស្សមានផ្ទៃពោះត្រូវយើងជូនកន្លែងអង្គុយទៅមនុស្សទាំងនោះ ។

លើរថក្រុងក្ដី តាមវិថីក្ដី បើមានអ្នកផងណាសួរព័ត៌មានអ្វីមួយដល់យើង យើងត្រូវជូនសារព័ត៌មានទៅគេ ដោយរាក់ទាក់ ដោយក្ដីទន់ភ្លន់ ដោយចិត្តចង់យកអាសា ។ ចំពោះបរទេស បើយើងឱ្យព័ត៌មានបានល្អ ជាការប្រសើរលើកកិត្តិយសជាតិយើងយ៉ាងអនេក ។

## មេរៀនទី ៤៨ - តាមបណ្ដោយវិថី

តាមចិញ្ចើមវិថី ក៏មានសុភាវធម៌ទៀត ។ កុមារមិនត្រូវហ្លួងហែងចិញ្ចើមវិថីឡើយ ដោយដើរជាដុំ ជាក្រុម ឬដើរឥតសណ្ដាប់ធ្នាប់ ដើរបណ្ដើរបន្លែងគ្នាបណ្ដើរ ។

បើឃើញកូនក្មេង ឬមនុស្សចាស់ត្រូវការដើរឆ្លងកាត់វិថី យើងត្រូវទៅជួយដឹកដៃកូនក្មេង ឬមនុស្សជរានោះ ដឹកដៃដោយមើលនាយអាយចៀសវាងគ្រោះថ្នាក់ កុំឱ្យរថយន្តមកប៉ះទង្គិចបាន កុំដឹកដៃឱ្យដើរលឿនពេកកញ្ចក់ ឬបំភ័យត្រូវធ្វើឡើងឱ្យសមរម្យ ។ បើជនទាំងនោះមានរបស់យួរ ត្រូវយើងជួយយួរផង ។

## មេរៀនទី ៤៩ - រោងទស្សនីយភាព

សុភាវធម៌នៅរោងទស្សនីយភាព(ភាពយន្ត - ល្ខោនសិល្បៈ - របាំ - តន្ត្រី ជាដើម) រឿងនេះជារឿងបន្ថែមមួយទៀត ។ អ្នកខ្លះខ្វះសុភាវធម៌នៅក្នុងរោងទស្សនីយភាព គ្រឡប់ទៅជាធ្វើឱ្យឮសម្លេងរំខានអ្នកឯទៀតដោយការបរិភោគ ឬដោយនិយាយគ្នា ។ តាមបទសុភាវធម៌ត្រូវមករោងទស្សនីយភាពឱ្យទាន់ពេលវេលា ។ បើយើងមកមិនទាន់ហើយចូលទៅក្នុងរោងពេលសិល្បៈកំពុងសម្ដែង ជាបទរំខានទស្សនិកជនឯទៀត និងរំខានសិល្បករយ៉ាងអនេក ។

នៅពេលដែលសិល្បករកំពុងសម្ដែង អន្លើខ្លះដែលសមរម្យទស្សនិកជនត្រូវសម្ដែងចិត្តអបអរដោយទះដៃ ។ ការទះដៃនេះទៀត ត្រូវលៃឱ្យត្រូវបែបបទ កុំទះខុសទំនង កុំទះបញ្ឆោរជ្រុលជាបទរំខានសិល្បករ ទៅវិញ ។

កុមារត្រូវយល់ថា នៅសម័យនេះសិល្បករជាពលរដ្ឋថ្លៃថ្នូរ មិនមែនជាជនថោកទាបដែលយើងត្រូវហៅ អា មឹង ឬមើលងាយ មើលថោកឡើយ ។

ផ្ទុយទៅវិញ គោរងដឹងថា សិល្បករជាជាងចម្លាក់វិស្វករសន្តានមនោសញ្ចេតនា នឹងជាតំណាងជាតិខាង សិល្បៈវប្បធម៌ ។

យើងបានឃើញ សុភាវធម៌ នៅទីសាធារណៈ មានច្រើនជាអនេក ។ កុមារត្រូវចាំថា ៖

"កុមារមិនត្រូវភ្លេចខ្លួន ត្រូវមានសម្បជញ្ញៈក្នុងខ្លួនជានិច្ច ត្រូវប្រុងខ្លួនកុំឱ្យខ្លួនក្លាយទៅជាឧបសគ្គរំខាន សេចក្តីសុខរបស់អ្នកផង តាមបែបបទណាមួយ តែត្រូវប្រុងខ្លួន ដើម្បីយកអាសាគេ ដោយទឹកមុខរីករាយ និង ដោយសុទ្ធចិត្ត " ។

គ្រូមានសេរីភាពនិងឱកាសច្រើនជាងនេះទៅទៀត អំពីអាកប្បកិរិយា ដែលត្រូវប្រព្រឹត្តនៅកន្លែង សាធារណៈ តាមបទសុភាវធម៌ ។

# ជំពូកទី ៧
# សុភាពធម៌នៅពិធីបុណ្យសាសនា
# និងនៅវត្តអារាម



## មេរៀនទី ៨០ - អំពីសាសនា

រឿងនេះអាចមានកើតឡើងជាបញ្ហា អ្នកអប់រំខ្លះរមែងមានយោបល់ថា រឿងសាសនាជារឿងដោយឡែក ជារឿងជំនឿរបស់ពលរដ្ឋ ហើយពលរដ្ឋម្នាក់ៗ មានសិទ្ធិសេរីភាពជឿឬមិនជឿនូវសាសនា ។

យើងក៏យល់ស្របដូចអ្នកអប់រំទាំងនេះដែរ ។

សេចក្ដីតទៅនេះ ឥតជាបទអំពាវនាវហៅជនណា ឬណែនាំកុមារឱ្យជឿ ឬប្រព្រឹត្តនូវសាសនាណាមួយឡើយ ។ តែយើងគ្រាន់តែសុំវែកញែកតាមបទសុភាវធម៌ប៉ុណ្ណោះ ដែលណែនាំយើងឱ្យមានអាកប្បកិរិយាក្រៅស្របទៅតាមចំនួនភាគច្រើន ព្រោះមិនចង់ឱ្យអាកប្បកិរិយាយើងឈ្លើយតែម្នាក់ឯងទៅរំខានចិត្តអ្នកផង ។

ខ្មែរយើងភាគច្រើនជាអ្នកកាន់ព្រះពុទ្ធសាសនា ។ សាសនានេះដូចសាសនាឯទៀតមានទំនៀមទម្លាប់ មានបែបបទប្រតិបត្តិ មានពិធីបុណ្យដែលអ្នកស្រុកនិយមនាំគ្នាធ្វើតាមវត្ត ។

រឿងដែលគេធ្វើនោះខុសឬត្រូវ ក៏មិនមែនជាបញ្ហាដែលយើងលើកមកជជែកក្នុងពេលនេះ តែរឿងដែលយើងចង់ថានោះ គឺទៅតាមបទសុភាវធម៌ បើខ្មែរទាំងអស់ចេះសូត្រធម៌ទៅហើយ ហើយមានគ្រូបង្រៀនឬសិស្សអង្គុយស្ងៀមនោះជាការមិនសមរម្យទេ ។

យើងរស់ជាមួយខ្មែរ ត្រូវមានវាចាសមរម្យជាមួយខ្មែរ ហើយមិនចង់ឱ្យខ្មែរខូចចិត្តដោយសារយើង ចោទថាយើងជាពួកទំនើបអសែយសាសន៍ ។ ក្នុងមូលដ្ឋានគំនិតដូច្នេះឯង ទើបកើតមានសុភាវធម៌ក្នុងពិធីសាសនានៅវត្តអារាមដូចតទៅនេះ ៖

## មេរៀនទី ៨១ - រៀនសូត្រធម្ម

ពិធីបុណ្យនីមួយៗ តែងមានទម្លាប់ពិសេសរបស់គេ មានរបៀបចាត់តាំងពីការសម្លៀកបំពាក់ របៀបអង្គុយតាមកន្លែង របៀបសំពះនឹងថ្វាយបង្គំ របៀបអុជធូប របៀបប្រគេនចង្ហាន់ របៀបរក្សាទឹកមុខជាដើម ។ ដូច្នេះហើយ បើយើងចូលទៅក្នុងពិធីបុណ្យនីមួយៗ យើងមិនត្រូវបង្កក្ដីរឹករវក្នុងបុណ្យនោះទេ យើងតោងមានព័ត៌មានឱ្យច្បាស់ តើយើងត្រូវធ្វើដូចម្ដេចឱ្យត្រូវនឹងរបៀបគេ ស្លៀកពាក់យ៉ាងណា ឈរត្រង់ណា សំពះបែបដូចម្ដេច ។

យើងគង់ដឹងថា អ្នកជឿសាសនារមែងមានចិត្តប្រកាន់ជាទីបំផុត ព្រោះការគោរពចំពោះសាសនា ក៏គោរពដោយខ្ពស់បំផុតដែរ ។ ចុះបើយើងមានធ្វើការឆ្គង ការឆ្គងនោះក៏រីកធំអាក្រក់ឥតគណនា ។

គួរយើងចាប់អារម្មណ៍ថា អ្នកស្រុកសាមញ្ញខ្មែរ តែងពោលរអ៊ូរទាំពីយុវជនទំនើបខ្លះដែលកាន់ឫកថាខ្លួនជាអ្នកមិនមែនសាសនា ។ ម្ល៉ោះហើយពេលគេសំពះព្រះសង្ឃ ខ្លួនមិនសំពះ ពេលគេសូត្រធម៌ ខ្លួនមិនសូត្រ ត្រឡប់ជានិយាយពាក្យជំទាស់នឹងសាសនាខ្លួនផង ។

យុវជនណាប្រព្រឹត្តដូច្នេះ អាចចាត់ទុកថាប្រព្រឹត្តខុសពីបទសុភាវធម៌ពេញទី ។ ច្បាប់សុភាវធម៌បង្គាប់កូនខ្មែរធម្មតា ឱ្យចេះយ៉ាងហោចណាស់ត្រឹមចេះសំពះព្រះសង្ឃនិងសូត្រធម៌បានខ្លះ ហើយគោរពតាមទំនៀមទម្លាប់ខ្លះដែលខ្មែរយើងធ្លាប់និយាយរាប់ពាន់ឆ្នាំមកហើយ ។

# មេរៀនទី ៥២ - វត្ថុអារាម

ក្នុងវត្តសាសនាដដែល មានទីស្ថានខ្លះ មានវត្ថុខ្លះ មានរូបខ្លះជាទីគោរពដ៏ខ្ពង់ខ្ពស់ដល់សាសនា ។

ព្រះពុទ្ធសាសនាគឺវត្តអារាម គឺគម្ពីសៀវភៅ គឺព្រះពុទ្ធរូប ដើមពោធិព្រឹក្ស .....

គ្រឹស្តសាសនាគឺព្រះវិហារ គឺរូបព្រះឆ្កាង គឺសម្លេងជួង .....

សាសនាមហាម៉ាត់គឺវត្តមហាម៉ាត់ គឺទំនៀមទម្លាប់ចាមខ្លះ ដែលចាមគោរពមានពិធីថ្វាយបង្គំថ្ងៃ.....

ច្បាប់សុភាវធម៌ ទោះបីយើងមិនជឿសាសនានោះក៏ដោយ ក៏ត្រូវតែយើងគោរពទីស្ថាន វត្ថុនិងរូបទាំងនោះ ចៀសវាងធ្វើអំពើដែលប្រឆាំងតាមបទបញ្ញារបស់គេ ប្រៀបដូចជាសាសនាព្រះពុទ្ធ ហាមមិនឱ្យផឹកស្រា រួចយើងយកស្រាទៅផឹកក្នុងវត្ត សាសនាមហាម៉ាត់ឱ្យតមសាច់ជ្រូក យើងយកសាច់ជ្រូកទៅបរិភោគ នៅកន្លែងគេ ។

ខ្ពស់ជាងនេះទៅទៀត យើងមិនត្រូវប្រើមធ្យោបាយណាទៅបន្ថោកតម្លៃទីស្ថាន វត្ថុដែលគេបូជាឡើយ ។ ច្បាប់សុភាវធម៌បង្គាប់យើងថា បើមិនគោរពក៏កុំបន្ថោកតាមកាយវិការ តាមវាចា ។

# មេរៀនទី ៨៣ - សំពះព្រះសង្ឃ និងគោរពវត្ត

ចំពោះកូនខ្មែរ ការថ្វាយបង្គំព្រះសង្ឃជាកិច្ចត្រូវប្រព្រឹត្ត ដូច្នេះយើងត្រូវប្រព្រឹត្តឡើងដោយសមរម្យតាមក្បួនខ្នាត ។ បើអង្គុយបត់ជើងឬលុតជង្គង់ធ្វើដោយសណ្ដាប់ធ្នាប់ ដៃសំពះផ្គុំឡើងជារូបនិម្មិតផ្កាឈូកក្រពុំប្រណម្យសំពះលើកឡើងឱ្យសមរម្យ ឱ្យមានរៀបរៀបរយ មិនហុចដៃទៅមុខច្រងាងពេកឬតៀតជាប់នឹងខ្លួនពេក តែឱ្យល្មម ឱ្យមានទំនង ឱ្យសង្រួម ឱ្យជាសិល្បៈ ។

វត្តជាកន្លែងគោរព ជាកន្លែងដែលនាំឱ្យចិត្តស្ងប់ ។ ដូច្នេះ កុមារា កុមារីទៅវត្តអារាម ត្រូវមានសម្លៀកបំពាក់ឱ្យស្អាតបាត ឱ្យមានចិត្តថ្លា ដោយសារសម្លៀកបំពាក់នោះ តែឱ្យរាបសា កុំឱ្យឆើត កុំឱ្យស្រើបស្រាល កុំឱ្យហ៊ឺហាលេងខ្លួនទៅវិញ ។

សំដីសំដៅ កាយវិការ បរិយាកាសទូទៅក្នុងវត្ត ក៏ត្រូវរក្សាដោយនឹកក្នុងចិត្តថា ទីនេះជាទីសមរម្យ ជាទីរម្ងាប់អារម្មណ៍ ជាទីគោរពមិនមែនជាទីសប្បាយអាឡេអាឡូទេ ។

យើងរំឭកឡើងវិញថា យើងឥតត្រូវការជជែកពីជំនឿឬពីគុណសម្បទរបស់សាសនាណាទេ តែគ្រូត្រូវទម្លាប់ក្មេងឱ្យមានភាពសមរម្យក្នុងពិធីបុណ្យ សាសនា ក្នុងវត្តអារាម ក្នុងកន្លែងដែលអ្នកផងគោរពទៅតាមបទបញ្ញារបស់សុភាវធម៌ប៉ុណ្ណោះ ។

# ជំពូកទី ៨

# សុភាពធម៌ចំពោះជនបរទេស



# មេរៀនទី ៩៨ - ជនបរទេស

នគរខ្មែរបានឯករាជ្យហើយ ។ កិត្តិសព្ទខ្មែរក៏ខ្ចរខ្ចាខ្ពង់ខ្ពស់ឡើងវិញ ដោយខ្មែរបានចូលទៅក្នុងចំណោមសង្គមជាតិនៃសកលលោក ។

បរទេសដែលមកប្រទេសយើងចែកជាពីរសណ្ឋាន ៖

ក- បរទេសដែលមករួមរស់ក្នុងប្រទេសយើងតែម្តងដូចជា ៖ ចិន - ជនយៀកណាម - ក្លឹង្គ - បារាំង ។ល។

ខ- បរទេសដែលមកមួយដង មួយយាម

ចំពោះបរទេសប្រភេទទីមួយ ច្បាប់ប្រទេសរបស់យើងមានចែងស្រាប់ហើយ ។ បទសុភាវធម៌ណែនាំយើងមិនឱ្យប្រកាន់ជាតិខ្មែរជ្រុលទៅរំខានដោយចិត្តចង្អៀត មិនឱ្យជនបរទេសទាំងនោះរស់បានស្រួលក្នុងប្រទេសយើងដោយប្រើអាកប្បកិរិយាមិនសមរម្យ ឬសំដីសំដៅទ្រគោះបោះបោក ។

យើងត្រូវបញ្ជាក់ថា ច្បាប់សុភាវធម៌មិនមែនបង្រួញចិត្តយើងរហូតដល់ទៅឱ្យបរទេសលួចគំនិតបាននោះទេ ។

តាមធម្មតាជនបរទេស ត្រូវការព័ត៌មាន( សួរផ្លូវ-សួររកប្រៃសណីយ៍ សួរទស្សនីយភាព សួរកន្លែងបុរាណវត្ថុ សួរទំនៀមទម្លាប់....) យើងត្រូវឱ្យព័ត៌មាននោះដោយរាក់ទាក់ ។

បើឱកាសហុចឱ្យ យើងអាចណែនាំបង្ហាញប្រទេសយើង តើមានសភាពល្អ និងលក្ខណៈពិសេសយ៉ាងណាខ្លះ ។ ចៀសវាងកុំឱ្យបរទេសទាំងនោះ ធ្លាក់ទៅជួបនឹងមនុស្សពួកឆបោកឬឆក់ - លួច - ប្លន់ ។

សុភាវធម៌ចំពោះបរទេសនេះ គ្រាន់តែជាការស្នើបន្តិចប៉ុណ្ណោះ ។

# ជំពូកទី ៩

# យុវជនយើង និងការសរសេរសំបុត្រ

## មេរៀនទី ៨៥ - របៀបផ្ញើសំបុត្រ

យើងមិនអធិប្បាយពីអត្ថបទសំបុត្រនោះទេ និយាយតែត្រង់បន្ទាប់ពីបានអត្ថបទហើយ ដាក់ក្រដាស ទៅក្នុងស្រោម កាខ្ទង់សំបុត្រ បិទតែមប្រ៍ ប៉ុណ្ណោះ ។ ខ្មែរយើងមិននិយមសរសេរសំបុត្រឆ្លើយឆ្លងគ្នាជាញឹក ញាប់ទេ ច្រើនតែវាហ៊ីៗ ទៅ ត្រូវការផ្ញើសំបុត្រម្តងៗ ដោយមានការខានពុំបាន ក៏ខ្វះក្រដាស់ត្រឹមត្រូវ ខ្វះស្រោម សំបុត្រ ខ្វះតែមប្រ៍ ដោយកន្លែងលក់តែមប្រីសោតទៀតក៏នៅឆ្ងាយពីផ្ទះ ។

ដូច្នេះសំបុត្រដែលផ្ញើនោះ ផ្ញើដោយខ្ចីខ្ចា កម្រមានជនណាធ្វើតាមក្បួនខ្នាតឡើយ ។ គ្រួសារខ្មែរសម័យ គួរមានទិញក្រដាស់ ស្រោម តែម ទុកក្រែងមានរវល់ត្រូវផ្ញើសំបុត្រ ។ មានហើយ គួរទម្លាប់ខ្លួន ទម្លាប់កូនចៅ ឱ្យមានការសរសេរឆ្លើយឆ្លងនិងមិត្តសម្លាញ់ និងគ្រួសារដែលនៅឆ្ងាយឱ្យបានញឹកញាប់បន្តិច ។

អង្គការអន្តរជាតិខ្លះ ក្នុងគំនិតចង់ឱ្យយុវជនក្នុងលោកទាំងមូលចេះទាក់ទងគ្នា រាប់អានគ្នា ដើម្បីឱ្យមាន ការយោគយល់គ្នារវាងជាតិនិងជាតិ បានទាំងស្នើសុំទៅអង្គការប្រៃសណីយ៍សកល កុំឱ្យមានការបិទតែមប្រ៍លើ សំបុត្រផង ។

គ្រួសារសម័យខ្លះ គេនិយមឱ្យកូនចៅមានមិត្តនៅបរទេស ។ សិស្សខ្មែរយើង ដែលចេះភាសាបារាំង បានបន្តិចបន្តួចដែរ អាចឆ្លើយឆ្លងបាននិងសិស្សជាតិបារាំង ស្វីស បិល្ស កាណាដាខ្លះបាន ។

ដើម្បីដោះស្រាយបញ្ហាភាសា យុវជនច្រើនប្រទេសនាំគ្នារៀន នឹងប្រើភាសាតែមួយ សម្រាប់លោក ទាំងមូល ។ ភាសានេះ ដែលគេបានបង្កើតជាង ៦០ឆ្នាំមកហើយ មានឈ្មោះថា "អឺស្ពេរ៉ង់តូ"(espéranto) ។

ប្រយោជន៍នៃការឆ្លើយឆ្លងសំបុត្រគ្នាបែបនេះ មានវែងឆ្ងាយណាស់ ៖ រៀនភាសា រៀនប្រវត្តិសាស្ត្រ ភូមិ សាស្ត្រ សន្សំទុកតែមប្រ៍ចំឡែកៗ រូបភាពប្លែកៗ ។ល។

## មេរៀនទី ៨៦ - សុនាវធម៌ក្នុងរបៀបផ្ញើសំបុត្រ

ក្រដាសសរសេរ៖ បើសំបុត្រនិងធ្វើដំណើរដោយអាកាសយាន គេប្រើក្រដាសស្តើង ដើម្បីចៀសវាង ចំណាយច្រើនទៅលើថ្លៃតែមប្រ៍ ។ កុំបត់ក្រដាសជាច្រើនផ្នត់ពេក មុននឹងដាក់ទៅក្នុងស្រោម ។ ឥឡូវគេច្រើន

និយមឱ្យមានផ្ទត់ក្រដាសលើសាច់អត្ថបទតែមួយ ឬពីរ តាមបណ្ដោយក្រដាស ។ នេះជាបទសុភាវធម៌ចំពោះអ្នកទទួលសំបុត្រ ។

ស្រោម៖ គេច្រើននិយមប្រើស្រោមវែងជាងមុន ដើម្បីចៀសវាងការបត់ក្រដាសខាងក្នុងជាច្រើនផ្ទត់ ។ បើសំបុត្រផ្ញើដំណើរតាមអាកាសយានគេច្រើនប្រើស្រោមស្ដើង ។ ស្រោមដែលមានលក្ខណៈត្រឹមត្រូវមានទំហំ ១១០មម x ១៤៥មម ស្រោមយ៉ាងតូចបំផុតមានទំហំ ៧០មម x ១០០មម ។

ជាបទសុភាវធម៌ចំពោះអ្នកទទួលសំបុត្រ គួរយើងបិទតែមប្រ៍ឱ្យគ្រប់គ្រាន់តាមកំរិតប្រៃសណីយ៍ ចៀសវាងកុំឱ្យមានការពិន័យនាំរំខានដល់អ្នកទទួល ។

សរសេរឈ្មោះក្នុងអាស័យដ្ឋានទៀត ក៏ត្រូវសរសេរឱ្យត្រូវមែនទែន ។ អ្នកទទួលមិនសប្បាយចិត្តទេ ដោយឃើញការសរសេរខ្ជីខ្ជា ឬខុស ឬប្រហាក់ប្រហែល ។ គេអាចមិនព្រមទទួលសំបុត្រនោះក៏សឹងបាន ។

- បិទតែមប្រ៍ឱ្យត្រូវកន្លែង គឺជ្រុងខាងលើហើយខាងស្ដាំខ្នងស្រោម ជាបទសុភាវធម៌ចំពោះភ្នាក់ងារប្រៃសណីយ៍ ដែលគេឥឡូវប្រើម៉ាស៊ីនសម្រាប់ធ្វើតែមប្រ៍ ឱ្យទៅជាមោឃៈ ។

សំបុត្រដែលបិទតែមប្រ៍ខុសកន្លែង គេដលស្រង់ចេញ ដើម្បីប្រថាប់ត្រាដោយដៃផ្ទាល់នាំឱ្យយូរការ ។ ជាបទសុភាវធម៌ចំពោះភ្នាក់ងារប្រៃសណីយ៍ទៀត បើកាលណាត្រូវការប្រើតែមប្រ៍ច្រើន ពីរ ឬបី បួន គួរកុំបិទតែមប្រ៍នោះ តែពាសច្រើនកន្លែង នាំឱ្យខាតពេលប្រថាប់ត្រា ។

- សំបុត្រដែលផ្ញើទៅបរទេស គួរមានការផ្ចិតផ្ចង់ជាងនេះទៅទៀត ។ របៀបធ្វើសំបុត្រអាចឆ្លុះឱ្យឃើញដល់វឌ្ឍនភាពនៃខ្មែរយើងបាន ។ គេនិយមសន្សំតែមប្រ៍ប្លែកៗទុក ។ តែមប្រ៍មានតម្លៃទាល់តែបិទដោយផ្ចិតផ្ចង់ មិនរហែក នៅមាន"ធ្មេញ" គ្រប់ ។ តែមប្រ៍ដែលភ្នាក់ងារប្រៃសណីយ៍ធ្វើឱ្យមោឃៈ ដោយប្រើម៉ាស៊ីនមិនសូវមានតម្លៃ បើចង់ឱ្យមានតម្លៃ អ្នកផ្ញើអាចទៅជួបភ្នាក់ងារប្រៃសណីយ៍ផ្ទាល់ សុំឱ្យភ្នាក់ងារនោះបោះត្រាយ៉ាងពិសេស ដោយដៃលើតែមប្រ៍សំបុត្រ ។ នេះជាភារៈផ្ទាល់នៃក្រសួងប្រៃសណីយ៍ដែលគេបំពេញដោយរីករាយ ។ តែមប្រ៍នៃប្រៃសណីយ៍ខ្មែរយើង បរទេសគេរាប់អានណាស់ គេចង់បានទុកណាស់ ។

## មេរៀនទី ៨៧ - គួរធ្វើតាមកំរិតខាងក្រោមនេះ ក្នុងរបៀបការខ្ទងសំបុត្រ






សៀវភៅនេះជាលើកដំបូង សម្រាប់ជាជំនួយដល់គ្រូបង្រៀនក្នុងការអនុវត្តន៍កម្មវិធីសិក្សាថ្មី ។ បន្ទាប់ពីនេះ នឹងមានការផ្សាយ សៀវភៅសុភាវធម៌ទៀតផ្នែកសិស្ស ។ គ្រូនិងអ្នកមើលទាំងឡាយ បើសង្កេតឃើញថាមានខុសឆ្គងត្រង់ណា មេត្តាជួយស្នើយោបល ដោយមកជួបនឹងយើងផ្ទាល់ ឬផ្ញើជាសំបុត្រមកដល់អ្នកនិពន្ធ ៖

**ឈួក ម៉ឹង ម៉ៅ**

" ចាងហ្វាងទីចាត់ការកិច្ចការគរុកោសល្យ ក្រសួងសិក្សាធិការជាតិ "

ភ្នំពេញ ថ្ងៃ ២៩ -១០ -៥៨